❖ ភិក្ខុខ្ចីវស្សាឬភិក្ខុចាស់សូម្បីបួសបាន៦០វស្សាហើយបើល្ងង់ខ្លៅពុំស្គាល់កិច្ចខុសត្រូវក្នុងវិន័យទេជាអនិស្សយមុត្តក។

📖 និស្សយមុត្តិកា ពាក្យផ្ទុយ អនិស្សយមុត្តិកា

និស្សយមុត្តិកា ន. (ឋា.) ភិក្ខុនីដែលមានវស្សាតាំងពី៥ឡើងទៅហើយចេះវិន័យមានសេចក្តីអៀនខ្មាសគ្រប់គ្រាន់ អាចផុតចាកនិស្ស័យរបស់ឧបជ្ឈាយ៍ឬអាចារ្យបានគឺអាចនៅតាមចំនើងខ្លួនបាន (ព.វិ.ពុ.)។

អនិស្សយមុត្តិកា ន. (ឋា.) ស្ត្រីអ្នកដែលមិនទាន់រួចផុតអំពីនិស្ស័យ គឺស្ត្រីអ្នកដែលនៅក្នុងបន្ទុកឬក្នុងអំណាចគេទូន្មានប្រៀនប្រដៅស្តីថា :

❖ បុត្រប្រុសស្រីដែលនៅក្នុងបន្ទុកមាតាបិតាជាអនិស្សយមុត្តិកា

❖ ភិក្ខុនីខ្លីវស្សាឬភិក្ខុនីចាស់សូម្បីបួសបាន៦០វស្សាហើយបើល្ងង់ខ្លៅពុំស្គាល់កិច្ចខុសត្រូវក្នុងវិន័យទេជាអនិស្សយមុត្តិកា។

📖 **នីហរ័ណ ពាក្យផ្ទុយ អាហរ័ណ**

នីហរ័ណ *ន.* (**ប.ក្ត.**) ជំនួញនាំចេញ, ជំនួញខាងដឹកនាំទំនិញចេញពីប្រទេសរបស់ខ្លួនទៅលក់ឯប្រទេសក្រៅ, មុខរបរពាណិជ្ជកម្មខាងដឹកនាំវត្ថុផ្សេងៗទៅលក់ឯបរទេស :

❖ ខ្ញុំប្រកបមុខរបរខាងនីហរ័ណ។

អាហរ័ណ *ន.* (**ប.ក្ត.**) មុខរបរខាងទទួលទំនិញ, មុខរបរខាងទទួលផលិតផលផ្សេងៗពីប្រទេសក្រៅនាំចូលមកក្នុងប្រទេស :

❖ ប្រកបមុខរបរខាងអាហរ័ណ។

📖 **នេះ ពាក្យផ្ទុយ នោះ**

នេះ *សព្វ.* ពាក្យសម្រាប់បង្ហាញ, ពាក្យសម្រាប់ចង្អុលអ្វីៗដែលនៅខាងខ្លួនឱ្យឃើញជាក់ច្បាស់ :

❖ សំបុត្រនេះ

❖ សេចក្តីនេះ។

នោះ *ន.ស.* ពាក្យសម្រាប់បង្ហាញ, ពាក្យសម្រាប់ចង្អុលអ្វីៗដែលនៅឆ្ងាយ

តែប្រាកដ; ជាពាក្យមានសូរសំឡេងស្មើនឹង ទុះ ប៉ុន្តែទាបជាង ទុំ, ដូចជា :

❖ សេចក្តីនោះ

❖ ផ្ទះនោះជាដើម។

📖 បង្ហូញ, អង្ហុញ ពាក្យផ្ទុយ សណ្ឆាក

បង្ហូញ *កិ.* ធ្វើឱ្យរួញ, ធ្វើឱ្យខ្ជីទៅវិញ :

❖ បង្ហូញសេចក្តីឱ្យខ្ជី។

អង្ហុញ *កិ.* បង្ហូញជើងចូល, បង្ហូញដៃចូល :

❖ អង្ហុញជើង។

សណ្ឆាក *កិ.* លាតលាត្រង់ស្អុក :

❖ សណ្ឆាកជើង។

📖 បច្ចុគ្គមនៈ ពាក្យផ្ទុយ អនុគ្គមនៈ

បច្ចុគ្គមនៈ *ន.* (**ឃ.ភ្ជ.**) ការក្រោកទទួល។

អនុគ្គមនៈ *ន.* (**ឃ.ភ្ជ.**) ការក្រោកជូន, ការតាមជូនដំណើរ :

❖ ធ្វើអនុគ្គមនៈ។

📖 បច្ចុគ្គមន៍ ពាក្យផ្ទុយ អនុគ្គមន៍

បច្ចុគ្គមន៍ *ន.* (**ឃ.ភ្ជ.**) ការក្រោកទទួល។

អនុគ្គមន៍ *ន.* (ឯ.ភ្ន.) ការក្រោកជូន, ការតាមជូនដំណើរ :

❖ ធ្វើអនុគ្គមន៍។

📖 បច្ចុគ្គមនាការ ពាក្យផ្ទុយ អនុគ្គមនាការ

បច្ចុគ្គមនាការ *ន.* (ឯ.) អាការៈនៃការក្រោកទទួល។

អនុគ្គមនាការ *ន.* (ឯ.) អាការៈនៃការក្រោកជូន :

❖ ធ្វើអនុគ្គមនាការ។

📖 បច្ឆាចារ្យ ពាក្យផ្ទុយ បុព្វាចារ្យ

បច្ឆាចារ្យ *ន.* (ឯ. និង **សំ.ភ្ន.**) អាចារ្យក្រោយ, គ្រូខាងក្រោយ :

❖ គ្រូបង្រៀនជាបច្ឆាចារ្យនៃបុត្រធីតាទាំងឡាយ។

បុព្វាចារ្យ *ន.* (ឯ. និង **សំ.ភ្ន.**) អាចារ្យមុន, គ្រូដើម គឺមាតាបិតា។ មាតាបិតាបានជាហៅថាបុព្វាចារ្យ ព្រោះជាគ្រូបង្ហាត់បង្រៀនកូនឱ្យចេះនិយាយស្តីនិងសណ្តាប់ធ្នាប់របៀបរបប ព្រមទាំងកិច្ចការទាំងពួងផងជាមុនជាងគ្រូទាំងអស់ដែលកូនត្រូវរៀនចំណេះវិជ្ជាផ្សេងៗ។

📖 បច្ឆាភត្ត ពាក្យផ្ទុយ បុរេភត្ត

បច្ឆាភត្ត *ន.* (ឯ.) វេលាខាងក្រោយភត្តគឺវេលាដែលបរិភោគភោជនាហារថ្ងៃត្រង់រួចហើយតាំងពីរសៀលទៅ :

❖ វេលាបច្ឆាភត្ត

❖ សម្រាកកាយក្នុងបច្ឆាភត្ត។

បុរេតត្ត *ន.* (**ឯ.**) វេលាមុនភត្ត គឺពេលមុនបរិភោគបាយថ្ងៃត្រង់។

📖 បច្ឆាតត្តកាល ពាក្យផ្ទុយ បុរេតត្តកាល

បច្ឆាតត្តកាល *ន.* (**ឯ.**) វេលាខាងក្រោយភត្ត គឺវេលាដែលបរិភោគភោជនាហារថ្ងៃត្រង់រួចហើយតាំងពីរសៀលទៅ :

❖ វេលាបច្ឆាភត្តកាល

❖ សម្រាកកាយក្នុងបច្ឆាភត្តកាល។

បុរេតត្តកាល *ន.* (**ឯ.**) វេលាមុនភត្ត គឺពេលមុនបរិភោគបាយថ្ងៃត្រង់។

📖 បច្ឆាតត្តកិច្ច ពាក្យផ្ទុយ បុរេតត្តកិច្ច

បច្ឆាតត្តកិច្ច *ន.* (**ឯ.**) ពេលខាងក្រោយនៃភត្តកិច្ច, វេលាខាងក្រោយបន្ទាប់ពីពេលបាយថ្ងៃត្រង់។

បុរេតត្តកិច្ច *ន.* (**ឯ.**) ពេលមុននៃភត្តកិច្ច, ពេលមុនបរិភោគបាយថ្ងៃត្រង់។

📖 បច្ឆិមភាគ ពាក្យផ្ទុយ បុព្វភាគ

បច្ឆិមភាគ *ន.* (**ឯ.**) ភាគខាងចុង។

បុព្វភាគ *ន.* (**ឯ.**) ចំណែកខាងដើម, ប៉ែកខាងដើម។

📖 **បញ្ញត្ត** **ពាក្យផ្គុំ** **អនុញ្ញាត**

បញ្ញត្ត *គុ.* ឬ *នា.* (ឆ.) ហាមប្រាមហើយ; តែងតាំងហើយ, តាំងទុកហើយ, រៀបចំហើយ; ដែលគេហាមប្រាមហើយ :

❖ រាជការបញ្ញត្តមិនឱ្យប្រជាជនលេងល្បែងភ្នាល់ផ្សេងៗ។

អនុញ្ញាត *កិ.* (ឆ.) យល់ព្រម, បើកឱកាសឱ្យ; បានយល់ព្រមហើយ :

❖ រដ្ឋាភិបាលបានអនុញ្ញាតឱ្យធ្វើការនោះហើយ។

📖 **បញ្ញត្តិ** **ពាក្យផ្គុំ** **អនុញ្ញាត**

បញ្ញត្តិ *ន.* (ឆ.) សេចក្តីហាមប្រាម, បម្រាម, សេចក្តីដែលគេតែងតាំង, សេចក្តីដែលគេរៀបចំ; ពាក្យដែលគេកំណត់ហៅ :

❖ មានបញ្ញត្តិ

❖ ធ្វើខុសនឹងបញ្ញត្តិ។

អនុញ្ញាត *កិ.* (ឆ.) យល់ព្រម, បើកឱកាសឱ្យ; បានយល់ព្រមហើយ :

❖ រដ្ឋាភិបាលបានអនុញ្ញាតឱ្យធ្វើការនោះហើយ។

📖 **បដិណេម** **ពាក្យផ្គុំ** **អនុណេម**

បដិណេម *គុ.* ឬ *ន.* (ឆ.) ដែលច្រាសឡើងវិញ; ដំណើរច្រាសមកវិញ, ដំណើរទទឹងទាស់ :

❖ រំពឹងជាអនុលោមនិងបដិលោម។

អនុលោម *កិ.* (ឆ.) តាមរោមគឺបណ្តោយ; បណ្តោយតាម, យល់ព្រមតាម, មិនទទឹងទាស់, មិនយល់ទាស់ :

❖ អនុលោមរកគ្នា។

📖 បណ្ឌិត ពាក្យផ្ទុយ ពាល

បណ្ឌិត *ន.* (ឆ.) ជនអ្នកមានប្រាជ្ញាឈ្លោះបណ្ឌា, ជនអ្នកប្រព្រឹត្តល្អ គឺអ្នកកាន់សុចរិត១០ប្រការដោយពិស្តារ, កាន់សុចរិត៤០ប្រការដោយខ្ជាប់ខ្ជួនហ្មត់ចត់ជានិច្ច; អ្នកប្រាជ្ញខាងផ្លូវសុចរិតយុត្តិធម៌ (ព.ពុ.)។

ពាល *ន.* (ឆ.សំ.) ទន់; ដែលនៅក្មេង; ល្ងង់, ខ្លៅ, មិនឈ្លាស; កាច, សាហាវ; អាក្រក់។

📖 បណ្ឌិតមានិនី ពាក្យផ្ទុយ ពាលមានិនី

បណ្ឌិតមានិនី *ន.* (ឆ.) ស្ត្រីអ្នកមានមានៈថាខ្លួនជាបណ្ឌិត; មានអត្ថន័យថាស្ត្រីអ្នកមានចំណេះវិជ្ជាប្រកាន់ថា គ្មានអ្នកណាមានចំណេះស្មើនឹងខ្លួន (ស្ត្រីអ្នកនេះស្គាប់ចំណេះត្រឹមតែប៉ុណ្ណឹង); ស្ត្រីអ្នកមានចំណេះព្រួលៗប្រកាន់ថាឥតមានអ្នកណាចេះជាងខ្លួន (ស្ត្រីអ្នកនេះអស់មានផ្លូវចេះតទៅទៀត គឺមានតែរេចរិលចំណេះនោះទៅវិញ)។

ពាលមានិនី ន. (ឆ.) ស្ត្រីអ្នកដឹងខ្លួន, ស្ត្រីអ្នកសម្គាល់ខ្លួនថាជាពាលឬថាល្ងង់ គឺបុគ្គលណាពាលល្ងង់ក៏ភ្ញាក់ខ្លួនថា ខ្លួនល្ងង់ពិតមែន, បុគ្គលនោះអាចនឹងប្រែគំនិតខំប្រឹងរៀន ខំប្រឹងស្តាប់ ក៏ត្រលប់ជាស្ត្រីអ្នកចេះដឹងស្គាល់ខុសត្រូវបានពុំខាន។

📖 បណ្ឌិតមានី ពាក្យផ្ទុយ ពាលមានី

បណ្ឌិតមានី ន. (ឆ.) អ្នកមានមានះថាខ្លួនជាបណ្ឌិត; មានអត្ថន័យថា អ្នកមានចំណេះវិជ្ជាប្រកាន់ថា គ្មានអ្នកណាមានចំណេះស្មើនឹងខ្លួន (អ្នកនេះស្តាប់ចំណេះត្រឹមតែប៉ុណ្ណឹង); អ្នកមានចំណេះព្រួលៗប្រកាន់ថា ឥតមានអ្នកណាចេះជាងខ្លួន (អ្នកនេះអស់មានផ្លូវចេះតទៅទៀត គឺមានតែរេចរិលចំណេះនោះទៅវិញ)។

ពាលមានី ន. (ឆ.) អ្នកដឹងខ្លួន, អ្នកសម្គាល់ខ្លួនថាជាពាលឬថាល្ងង់គឺបុគ្គលណាពាលល្ងង់ក៏ភ្ញាក់ខ្លួនថាខ្លួនល្ងង់ពិតមែន, បុគ្គលនោះអាចនឹងប្រែគំនិតខំប្រឹងរៀនខំប្រឹងស្តាប់ ក៏ត្រលប់ជាអ្នកចេះដឹងស្គាល់ខុសត្រូវបានពុំខាន។

📖 បន្ដឹច ពាក្យផ្ទុយ បន្ធូរ

បន្ដឹច ភិ. ធ្វើឱ្យតឹង, ទាញឱ្យតឹង, តឿនតឹងរុឹងរឿយៗ :

❖ សុំកុំបន្ដឹងខ្លាំងពេក។

បន្ធូរ *ភិ.* ធ្វើឱ្យធូរគឺធ្វើមិនឱ្យតឹងមិនឱ្យចង្អៀតពេក :

❖ បន្ធូរខ្សែក្រវាត់។

📖 **បន្ទាប់ ពាក្យផ្ទុយ មុន**

បន្ទាប់ *ភិ.ន.* ឬ *ន.* ដែលផ្ទាប់ជិតគ្នា, ដែលរងលំដាប់ពីគ្នា, ដែលឋិតនៅក្បែរគ្នា។

មុន *ភិ.ន.* ឬ *ន.* ដែលកើត, ផ្តើម, ស្ថិតនៅជាដំបូង, ស្ថិតនៅជាដើមគេ។

📖 **បមាន ពាក្យផ្ទុយ អប្បមាន**

បមាន *ន.* (ឃ.) ការភ្លេចស្មារតី, ការធ្វេសស្មារតី, សេចក្តីប្រហែស, ការធ្វេសប្រហែស។

អប្បមាន *ន.* (ឃ.) សេចក្តីមិនធ្វេស, សេចក្តីមិនប្រហែស, សេចក្តីមិនធ្វេសប្រហែស; ការមិនធ្វេសស្មារតី; ការប្រុងប្រយត្នជានិច្ច, ការប្រុងមិនឱ្យភ្លាំងភ្លាត់; ការប្រយត្នមិនធ្វើអំពើអាក្រក់។

📖 **បរលោក ពាក្យផ្ទុយ ឥហលោក**

បរលោក *ន.* (ឃ.) លោកឯមុខ :

❖ ធ្វើមរណកាលទៅកាន់លោកឯខាងមុខ។

ឥហលោក *ន.* (ឃ.) លោកនេះ, ដលោក :

❖ ប្រយោជន៍ក្នុងឥធលោកនិងបរលោក។

📖 បរលោកត្តភាព ពាក្យផ្ទុយ ឥធលោកត្តភាព

បរលោកត្តភាព *ន.* (ឋា.ក្ត.) ជាតិខាងមុខ។

ឥធលោកត្តភាព *ន.* (ឋា.ក្ត.) អត្តភាពក្នុងលោកនេះ គឺជាតិនេះ។

📖 បរលោកសុខ ពាក្យផ្ទុយ ឥធលោកសុខ

បរលោកសុខ *ន.* (ឋា.) សុខសម្រាប់ជាតិខាងមុខ។

ឥធលោកសុខ *ន.* (ឋា.) សុខក្នុងលោកនេះ គឺសុខសម្រាប់ជាតិនេះ។

📖 បរស្សបទ ពាក្យផ្ទុយ អត្តនោបទ

បរស្សបទ *ន.* (ឋា.) បទដើម្បីអ្នកដទៃ។

អត្តនោបទ *ន.* (ឋា.) បទដើម្បីខ្លួន។

📖 បរាជិន ពាក្យផ្ទុយ អត្តាជិន

បរាជិន *ន.* (ឋា.) អ្នកដែលលុះនៅក្នុងអំណាចអ្នកដទៃ, អ្នកដែលលុះនៅក្នុងបង្គាប់នៃអ្នកដទៃ។

អត្តាជិន *ន.* (ឋា.) អ្នកដែលមិនលុះនៅក្នុងអំណាចអ្នកដទៃ, អ្នកដែលមិនលុះនៅក្នុងបង្គាប់នៃអ្នកដទៃ។

📖 បាតរាស ពាក្យផ្ទុយ សាយមាស

បាតរាស *ន.* (**ឃ.សំ.**) អាហារពេលព្រឹក, អាហារព្រឹក, អាហារស្រស់ស្រួប :

- ធ្វើបាតរាស
- ពេលបាតរាស។

សាយមាស *ន.* (**ឃ.សំ.**) ភោជនដែលត្រូវបរិភោគវេលាល្ងាច, ភោជនល្ងាច :

- បរិភោគសាយមាស
- ពេលសាយមាស (ហៅ សាយរោជន ក៏បាន)។

📖 **ឃាត់ខ្លួន** **ពាក្យផ្ទុយ** **មានខ្លួន**

ឃាត់ខ្លួន *កិ.* គ្មានរូបនៅជាអាង។

មានខ្លួន *កិ.* មានរូបនៅជាអាង។

📖 **ឃាបកម្ម** **ពាក្យផ្ទុយ** **បុញ្ញកម្ម**

ឃាបកម្ម *ន.* (**ឃ.**) អំពើអាក្រក់។

បុញ្ញកម្ម *ន.* (**ឃ.**) អំពើដែលជាបុណ្យ។

📖 **ឃាបគ្រោះ** **ពាក្យផ្ទុយ** **សោមគ្រោះ**

ឃាបគ្រោះ *ន.* (**សំ.ក្ល.**) គ្រោះអាក្រក់, គ្រោះកាច។

សោមគ្រោះ *ន.* (**សំ.ក្ល.**) គ្រោះល្អ, គ្រោះជា។

📖 **បុគ្គលបរិសោត** **ពាក្យផ្ទុយ** **សព្ឋញ្ញូបរិសោត**

បុគ្គលបរិភោគ *ន.* (ឃ.) ការប្រើប្រាស់របស់ក្នុងអំណាចបុគ្គល។

សង្ឃបរិភោគ *ន.* (ឃ.) ការប្រើប្រាស់របស់ក្នុងអំណាចសង្ឃ។

📖 **បុគ្គលិក ពាក្យផ្ទុយ សង្ឃិក**

បុគ្គលិក *ន.* (ឃ.) ដែលចំពោះបុគ្គល, ដែលសម្រាប់បុគ្គលម្នាក់ៗមិនមែនជាសាធារណៈទូទៅ :

❖ របស់បុគ្គលិក។

សង្ឃិក *ន.* (ឃ.) ដែលជារបស់សង្ឃ។

📖 **បុគ្គលិកទាន ពាក្យផ្ទុយ សង្ឃាតិកទាន, សង្ឃទាន**

បុគ្គលិកទាន *ន.* (ឃ.) ទានដែលទាយកឱ្យចំពោះបុគ្គល គឺឱ្យសំដៅរូបបុគ្គលតាមស្មគ្រស្រលាញ់គាប់ចិត្តបុគ្គលណាឱ្យសំដៅបុគ្គលនោះ។

សង្ឃាតិកទាន *ន.* (ឃ.សំ.) ទានដែលបង្អោនទៅចំពោះសង្ឃ គឺទានដែលទាយកប្រគេនចំពោះសង្ឃ។

សង្ឃទាន *ន.* (ឃ.សំ.) ទានដែលទាយកប្រគេនចំពោះសង្ឃ។

📖 **បុគ្គលិកបរិភោគ ពាក្យផ្ទុយ សង្ឃិកបរិភោគ**

បុគ្គលិកបរិភោគ *ន.* (ឃ.) ការប្រើប្រាស់របស់បុគ្គលក្នុងកិច្ចការ, ការប្រើប្រាស់របស់បុគ្គលក្នុងអំណាចបុគ្គល។

សង្ឃិកបរិនោត *ន.* (ឥ.) ការប្រើប្រាស់របស់សង្ឃក្នុងកិច្ចការ, ការប្រើប្រាស់របស់សង្ឃក្នុងអំណាចសង្ឃ (ព.វិ.)។

📖 **បុនប្បុនភ្ពម្ហ** **ពាក្យផ្ទុយ** **អបុនប្បុភ្ពម្ហ**

បុនប្បុនភ្ពម្ហ *ន.* (ឥ.) កម្មដដែលៗ គឺអំពើដដែលៗ, កិច្ចការដដែលៗ, ការវល់ដដែលៗរបស់សត្វលោក។

អបុនប្បុនភ្ពម្ហ *ន.* (ឥ.) ខន្ធនិព្វានដែលឥតកម្មដដែលៗ។

📖 **បុប្ផព្រឹក្ស** **ពាក្យផ្ទុយ** **ផលព្រឹក្ស**

បុប្ផព្រឹក្ស *ន.* (ឥ. និង **សំ.ភ្ន.**) បុស្បព្រឹក្ស, ឈើដែលមានផ្កា។

ផលព្រឹក្ស *ន.* (ឥ. និង **សំ.ភ្ន.**) ឈើដែលមានផ្លែ គឺឈើដែលបញ្ចេញផ្កាហើយកកើតជាផ្លែផង។

📖 **បុព្វណ្ហៈ** **ពាក្យផ្ទុយ** **សាយណ្ហៈ**

បុព្វណ្ហៈ *ន.* (ឥ.**ភ្ន.**) សម័យជាខាងដើមនៃថ្ងៃ (ក្រោយបន្ទាប់បច្ចូសសម័យ) គឺវេលាព្រះអាទិត្យរះ (ពេលថ្ងៃរះ)។

សាយណ្ហៈ *ន.* (ឥ.**ភ្ន.**) វេលារសៀល, ពេលល្ងាច :

❖ វេលាសាយណ្ហៈ។

📖 **បុព្វណ្ហ** **ពាក្យផ្ទុយ** **សាយណ្ហ**

បុព្វណ្ហ *ន.* (**ឋា.**) សម័យជាខាងដើមនៃថ្ងៃ (ក្រោយបន្ទាប់បច្ចូសសម័យ) គឺ
វេលាព្រះអាទិត្យរះ (ពេលថ្ងៃរះ)។

សាយណ្ហ *ន.* (**ឋា.**) វេលារសៀល, ពេលល្ងាច :

❖ វេលាសាយណ្ហ។

🕮 **បុព្វណ្ហកាល ពាក្យផ្ទុយ សាយណ្ហកាល**

បុព្វណ្ហកាល *ន.* (**ឋា.**) សម័យជាខាងដើមនៃថ្ងៃ (ក្រោយបន្ទាប់បច្ចូសសម័យ)
គឺវេលាព្រះអាទិត្យរះ (ពេលថ្ងៃរះ)។

សាយណ្ហកាល *ន.* (**ឋា.**) វេលារសៀល, ពេលល្ងាច :

❖ វេលាសាយណ្ហកាល។

🕮 **បុព្វណ្ហសម័យ ពាក្យផ្ទុយ សាយណ្ហសម័យ**

បុព្វណ្ហសម័យ *ន.* (**ឋា.ភ្ន.**) សម័យជាខាងដើមនៃថ្ងៃ (ក្រោយបន្ទាប់
បច្ចូសសម័យ) គឺវេលាព្រះអាទិត្យរះ (ពេលថ្ងៃរះ)។

សាយណ្ហសម័យ *ន.* (**ឋា.ភ្ន.**) វេលារសៀល, ពេលល្ងាច :

❖ វេលាសាយណ្ហសម័យ។

🕮 **បំព្រៃប្រទេស ពាក្យផ្ទុយ បំផ្លាញប្រទេស**

បំព្រៃប្រទេស *កិ.* ធ្វើប្រទេសរបស់ខ្លួនឱ្យប្រហែលដូចជាព្រៃ។

បំផ្លឹះប្រទេស *កិ.* ធ្វើប្រទេសរបស់ខ្លួនឱ្យភ្លឺល្អតលាស់ចម្រើន, ធ្វើប្រទេសរបស់ខ្លួនឱ្យរុងរឿង, ធ្វើប្រទេសរបស់ខ្លួនឱ្យថ្កើងថ្កាន។

📖 បំព្រៃលោក ពាក្យផ្ទុយ បំផ្លឹះលោក

បំព្រៃលោក *កិ.* ញុំាងលោកឱ្យប្រហែលដូចជាព្រៃ :

❖ ព្រះសម្ពុទ្ធទ្រង់ប្រទានព្រះឱវាទថា ន សិយា លោកវឌ្ឍនោ “កុំធ្វើខ្លួនឱ្យជាមនុស្សបំព្រៃលោក”, មានអត្ថន័យថា កុំប្រព្រឹត្តអាក្រក់ហួសហេតុឱ្យមានខ្លួនប្រហែលដូចជាព្រៃទ្រុបទ្រុលឬប្រហែល ដូចជាចម្រុងចម្រឹង, ប្រហែលដូចជាដង្គត់ក្នុងលោកឱ្យគេទើសមុខទើសក្រោយ ឱ្យគេពិបាកចិត្តគំនិតអាប់អួចំបែងរាល់គ្នា។

បំផ្លឹះលោក *កិ.* ញុំាងលោកឱ្យភ្លឺ, ញុំាងលោកឱ្យរុងរឿង, ញុំាងលោកឱ្យប្រកបដោយសុចរិតយុត្តិធម៌, ញុំាងលោកឱ្យបានសុខស្ងប់ :

❖ អ្នកប្រាជ្ញទាំងឡាយជាមនុស្សបំភ្លឺលោក; ព្រះពុទ្ធនិងព្រះអរហន្តទាំងឡាយ ជាអ្នកបំភ្លឺលោកខាងការពន្យល់ឱ្យសត្វលោករាវរកធម៌ដើម្បីរំលត់ទុក្ខឃើញ។

📖 ប្រមាថ ពាក្យផ្ទុយ អប្រមាថ

ប្រមាថ *ន.* (សំ.) ការបៀតបៀនគេ, ការញុំាញ៉ីគេ, ការធ្វើទុក្ខបុកម្នេញឱ្យ

គេលំបាក; ការមើលងាយគេ។

អប្រមាថ *ន.* (*សំ.*) ការមិនបៀតបៀន; ការមិនធ្វើទុក្ខបុកម្នេញអ្នកដទៃ។

📖 ប្រមាទ ពាក្យផ្ទុយ អប្រមាទ

ប្រមាទ *ន.* (*សំ.*) ការភ្លេចស្មារតី, ការធ្វេសស្មារតី, សេចក្តីប្រហែស, ការធ្វេសប្រហែស។

អប្រមាទ *ន.* (*សំ.*) ការមិនភ្លេចស្មារតី, ការមិនធ្វេសស្មារតី, សេចក្តីមិនប្រហែស, ការមិនធ្វេសប្រហែស។

📖 ប្រយោគឯបត្តិ ពាក្យផ្ទុយ ប្រយោគសម្បត្តិ

ប្រយោគឯបត្តិ *ន.* (*សំ.*) ការមិនបរិបូរដោយកាយប្រយោគនិងវចីប្រយោគ គឺសភាពនៃបុគ្គលដែលអ្នកធំស្អប់, សភាពនៃបុគ្គលដែលអ្នកធំមិនស្គាល់ក៏ឃ្លាងចាកការឧបត្ថម្ភនៃអ្នកធំ :

❖ ប្រយោគវិបត្តិជាភាពរារាំងបាំងមុខកុសលមិនឱ្យចេញមុខផ្តល់ផលដល់បុគ្គលអ្នកបំពេញការកសាងបានឡើយ។

ប្រយោគសម្បត្តិ *ន.* (*សំ.*) ការបរិបូណ៌ដោយកាយប្រយោគនិងវចីប្រយោគ គឺសភាពនៃបុគ្គលដែលមានអ្នកធំស្រលាញ់រាប់អានកាន់ទ្រង់ក៏អាចញុំាងសេចក្តីចម្រើនឱ្យលូតលាស់កើតកើនបាន :

❖ ប្រយោគសម្បត្តិអាចរារាំងបាំងមុខបាបតិចតួចស្ពឹចស្តើងឱ្យងាស់គាំងចេញមុខឱ្យផលពុំកើត។

📖 ប្រាក់ដុំ ពាក្យផ្ទុយ ប្រាក់រាយ

ប្រាក់ដុំ *ន.* ប្រាក់ដុំដែលមិនរលែកចែកដោយឡែក។

ប្រាក់រាយ *ន.* ប្រាក់រាយរងដែលរលែកចេញដោយឡែក។

📖 ប្រែរឿងសេចក្តី ពាក្យផ្ទុយ ប្រែឈោតប្រយោគ

ប្រែរឿងសេចក្តី *កិ.* ប្រែពីភាសាមួយមកជាភាសាមួយ ដូចជាប្រែពីបាលីមកជាខ្មែរជាដើម, ក្នុងប្រយោគនីមួយៗមួយសង្កាត់ៗបណ្តោយពីខាងដើមរៀងទៅតាមដំណើរសេចក្តីមកជាខ្មែរ។

ប្រែឈោតប្រយោគ *កិ.* ប្រែពីបាលីឬពីសំស្រ្កឹតក្នុងប្រយោគមួយៗមកជាខ្មែរដោយឈោតផ្តោះតាមដំណើរសេចក្តីខ្មែរ។

📖 ជាសុក ពាក្យផ្ទុយ រងាសុក

ជាសុក *ន.* (ឥ.) សេចក្តីសុខ, សេចក្តីសម្រាន្ត, សេចក្តីសប្បាយ :

❖ នៅតាមផាសុក។

រងាសុក *ន.* (ឥ.) សេចក្តីមិនសប្បាយ; សេចក្តីអផ្សុក; សេចក្តីព្រួយចិត្ត; ដំណើរមិនស្រួលចិត្ត; ដំណើរមិនសូវបានសុខ, ការប្រដាក់ប្រទុក្ខ (ដោយ

ហេតុមានជំងឺតម្កាត់ជាដើម)។

📖 **ផ្កាប់** **ពាក្យផ្ទុយ** **ផ្ងារ**

ផ្កាប់ *អ.* ដាក់ត្រលប់យកមុខឬបាតចុះក្រោម, ដាក់ត្រលប់យកពោះចុះក្រោម :

❖ ផ្កាប់មុខ។

ផ្ងារ *អ.* ឬ *អ.ន.* ប្រែយកពោះមកខាងលើយកខ្នងទៅខាងក្រោមឬយកមុខមកខាងលើយកក្រោយទៅខាងក្រោម :

❖ ផ្ងារប្រអប់។

📖 **ផ្ទុយ** **ពាក្យផ្ទុយ** **ស្រប**

ផ្ទុយ *អ.ន.* ឬ *គ.* ដែលច្រាសត្រលប់, ដែលមិនស្របគ្នា, ដែលជាទំនាស់នឹងគ្នា :

❖ ពាក្យផ្ទុយ។

ស្រប *អ.ន.* ឬ *គ.* ដែលបណ្តោយតាមគ្នា; ដែលមានសូរសម្ផស្សចុងចួនត្រូវគ្នា :

❖ ពាក្យស្របគ្នា។

📖 **ផ្លាង** **ពាក្យផ្ទុយ** **សាំង, ស៊ាំ**

ផ្លាង *គ.* ដែលនៅផ្អើលភ្ញាក់មិនទាន់សាំង, ដែលមិនទាន់ស៊ាំ :

❖ គោផ្ដោង។

សាំង *ន.* ដែលមិនផ្ដោង, ដែលមិនផ្អើល, ដែលងាយឱ្យចាប់ឱ្យកាន់ (ចំពោះតែសត្វ) :

❖ មាន់សាំង។

ស្ទាំ *ន.* ថ្នឹក :

❖ ចិត្តស្ទាំ។

📖 ពទ្ធសីមា ពាក្យផ្ទុយ អពទ្ធសីមា

ពទ្ធសីមា *ន.* (ឋា.) ឈ្មោះសីមាមួយប្រភេទដែលសង្ឃសូត្រចងតាមលក្ខណៈច្បាប់វិន័យព្រះពុទ្ធសាសនាកំណត់ជាព្រំដែនសម្រាប់ធ្វើសង្ឃកិច្ចផ្សេងៗ :

❖ ពទ្ធសីមាវត្ត (ព.វិ.ពុ.)។

អពទ្ធសីមា *ន.* (ឋា.) សីមាដែលសង្ឃមិនបាច់សូត្រចង។ មាន៣យ៉ាង :

១- **គាមសីមា** : ព្រំដែនស្រុក។

២- **ឧទកុក្ខេបសីមា** : ព្រំដែនដែលសាចទឹកក្នុងទឹកនឹងធ្លាក់មិនហូរ។

៣- **អព្ភន្តរសីមា** : ព្រំដែនក្នុងព្រៃសុទ្ធដែលវាស់ប្រវែង៧អព្ភន្តរគឺ៤៩ព្យាមឬ១៩៦ហត្ថជុំវិញរៀងខ្លួន (ព.វិ.ពុ.)។

📖 ពហុព្យាឌ្ឍ ពាក្យផ្ទុយ ឯកព្យាឌ្ឍ

ពហុព្យាង្គ *ន.* ឬ *ន.* (**ឃ.**) សព្ទដែលមានព្យាង្គច្រើន គឺសព្ទឬសម្តីដែលមានសូរច្រើនម៉ាត់តាំងពីបីម៉ាត់ឡើងទៅ :

❖ កន្ទាទូក

❖ កន្ទក់កន្ទេញ។

ឯកព្យាង្គ *ន.* (**ឃ.**) ពាក្យមួយព្យាង្គដូចជា កត់, កប, កាត់, គង, ទំ, នំ ជាដើម ។

📖 **ពហុវចនៈ ពាក្យផ្ទុយ ឯកវចនៈ**

ពហុវចនៈ *ន.* (**ឃ.ភ្ន.**) ពាក្យសម្រាប់ប្រើក្នុងវេយ្យាករណ៍ប្រាប់ចំនួនច្រើន។

ឯកវចនៈ (**ឃ.ភ្ន.**) ពាក្យប្រាប់ចំនួនតែមួយឬតែម្នាក់, ដូចជា គុម្ពុយ, ភៅអីមួយ, ក្មេងម្នាក់ ជាដើម (ព.រ.)។

📖 **ពាហិរត្ថ ពាក្យផ្ទុយ អព្ភន្តរត្ថ**

ពាហិរត្ថ *ន.* (**ឃ.**) រូបសេចក្តីដែលនៅក្នុងពាហិរសញ្ញា (លេខក្រៅ)។

អព្ភន្តរត្ថ *ន.* (**ឃ.**) រូបសេចក្តីដែលនៅក្នុងអព្ភន្តរសញ្ញា (លេខក្នុង), ដូចជា កាលព្រះសក្យមុនីសម្មាសម្ពុទ្ធទ្រង់ជិតចូលបរិនិព្វានទ្រង់ត្រាស់ផ្តាំថា :

❖ អ្នកទាំងឡាយចូរកុំប្រមាទ!។

📖 **ពិរោធ ពាក្យផ្ទុយ អពិរោធ**

ពិរោធ *ន.* (**ឃ.សំ.ភ្ន.**) កំហឹង; កំហុស; សេចក្តីស្អប់; ជម្លោះ; សត្រូវ។

អពិរោធ *ន.* (ឃ.*សំ.ក្ល.*) សេចក្តីមិនពិរោធ; ដំណើរឥតកំហុស, ដំណើរឥតសេចក្តីស្អប់; អ្នកដែលឥតពិរោធ, អ្នកដែលឥតកំហុស។

📖 **ពិស្តារ　　ពាក្យផ្ទុយ　　សង្ខេប**

ពិស្តារ *ន.* (*សំ.ក្ល.*) សេចក្តីទូលាយ, សេចក្តីវែង; ដំណើរយឺតយូរ :

❖ និយាយដោយពិស្តារ។

សង្ខេប *ន.* (ឃ.) សេចក្តីបំប្រួញ, សេចក្តីយ៉ៃ :

❖ និយាយដោយសង្ខេប។

📖 **ពុទ្ធប្បញ្ញត្តិ　　ពាក្យផ្ទុយ　　ពុទ្ធានុញ្ញាត**

ពុទ្ធប្បញ្ញត្តិ *ន.* (ឃ.) បម្រាមព្រះពុទ្ធ គឺវិន័យដែលព្រះពុទ្ធទ្រង់ត្រាស់ហាមមិនឱ្យពួកបព្វជិតប្រព្រឹត្តកន្លងព្រោះទ្រង់យល់ថាជាទោសដែលអ្នកឫសត្រូវវៀរ។

ពុទ្ធានុញ្ញាត *ស.* ឬ *ន.* (ឃ.) វិន័យដែលព្រះពុទ្ធទ្រង់អនុញ្ញាត គឺដែលទ្រង់យល់ព្រមឱ្យធ្វើ, ដែលទ្រង់យល់ព្រមឱ្យប្រព្រឹត្ត, ដែលទ្រង់យល់ព្រមឱ្យប្រតិបត្តិព្រោះទ្រង់យល់ឃើញថាមានប្រយោជន៍ :

❖ វិន័យនេះជាពុទ្ធានុញ្ញាត, នុ៎ះជាពុទ្ធប្បញ្ញត្តិ (ព.វិ.ពុ.)។

📖 **ពុទ្ធិ　　ពាក្យផ្ទុយ　　អពុទ្ធិ**

ពុទ្ធិ *ន.* (**ឥ.សំ.**) ប្រាជ្ញា, ការយល់ :

❖ មនុស្សមានពុទ្ធិ។

អពុទ្ធិ *ន.* (**ឥ.សំ.**) សេចក្តីល្ងង់; ដំណើរមមិងមមាំង, ការមិនដឹងង៉ៃង៉ោះ; ការមិនយល់អ្វីសោះ :

❖ មនុស្សអពុទ្ធិ។

🕮 ពុំសូវមានព្រះអន្ត ពាក្យផ្ទុយ មានព្រះអន្ត

ពុំសូវមានព្រះអន្ត *ន.* (**ទ.ស.** ឬ **ស.ស.**) ស្គម។

មានព្រះអន្ត *ន.* (**ទ.ស.** ឬ **ស.ស.**) ធាត់។

🕮 ពោះដំឡើង ពាក្យផ្ទុយ ពោះសម្រក

ពោះដំឡើង *ន.* ផ្ទៃទឹកដែលឡើង, ផ្ទៃទឹកដែលកំពុងឡើង :

❖ ពោះដំឡើងទន្លេ

❖ ពោះដំឡើងស្ទឹង។

ពោះសម្រក *ន.* ផ្ទៃទឹកដែលស្រក, ផ្ទៃទឹកដែលកំពុងស្រក :

❖ ពោះសម្រកទន្លេ

❖ ពោះសម្រកស្ទឹង។

🕮 ឈ្បោនៈ ពាក្យផ្ទុយ សួបៈ

ព្យញ្ជនៈ *ន.* (ឋា.ភ្ន.) ម្ហូបក្រៅពីសម្ពទឹក :

- ម្ហូបខាប់
- ម្ហូបគោក
- ម្ហូបក្រៀម។

សូប: *ន.* (ឋា.ភ្ន.) សម្ពទឹក, ម្ហូបមានទឹក។

📖 **ព្យត្ត** **ពាក្យផ្ទុយ** **អព្យត្ត**

ព្យត្ត *ន.* (ឋា.) ដែលឈ្លាស, ដែលប៉ិន, ដែលវាងវៃ :

- មនុស្សព្យត្ត។

អព្យត្ត *ន.* (ឋា.) ដែលមិនឈ្លាស, ដែលមិនប៉ិន, ដែលមិនវាងវៃ :

- មនុស្សអព្យត្ត។

📖 **ព្យាបាទ** **ពាក្យផ្ទុយ** **អព្យាបាទ**

ព្យាបាទ *ន.* (ឋា.) ដំណើរចងចិត្តនឹងធ្វើអ្នកដទៃឱ្យវិនាស, សេចក្តីគុំកួន។

អព្យាបាទ *ន.* (ឋា.) ការមិនព្យាបាទ គឺការមិនចងគំនុំ, ការមិនគុំកួន។

📖 **ព្រហ្មចរិយ** **ពាក្យផ្ទុយ** **អព្រហ្មចរិយ**

ព្រហ្មចរិយ *ន* (ឋា) បែបបទរបស់ព្រហ្មចរិយ, សណ្តាប់ធ្នាប់របស់ព្រហ្មចរិយ; ការប្រព្រឹត្តធម៌ដ៏ប្រសើរ។ (ហៅ ព្រហ្មចរិយធម៌ ក៏បាន)។

អព្រហ្មចរិយ ន. (ឃ.) ការមិនប្រព្រឹត្តព្រហ្មចរិយ (ហៅអព្រហ្មចរិយធម៌ ក៏បាន)។

📖 **ព្រហ្មចារិនី ពាក្យផ្ទុយ អព្រហ្មចារិនី**

ព្រហ្មចារិនី ន. (ឃ.) ស្ត្រីអ្នកប្រព្រឹត្តធម៌ដ៏ប្រសើរ។

អព្រហ្មចារិនី ន. (ឃ.) ស្ត្រីអ្នកដែលមិនមែនជាព្រហ្មចារិនី។

📖 **ព្រហ្មចារី ពាក្យផ្ទុយ អព្រហ្មចារី**

ព្រហ្មចារី ន. (ឃ.) អ្នកប្រព្រឹត្តព្រហ្មចារ្យ។ ពាក្យនេះតាមលទ្ធិព្រាហ្មណ៍សំដៅយកអ្នកដែលកំពុងហាត់រៀនវេទ ឬអ្នកដែលកំពុងសិក្សាលទ្ធិសាសនាសំដៅយកអ្នកដែលកំពុងហាត់រៀនវេទ ឬសំដៅចំពោះតែអ្នកដែលរៀរមេថុនធម្មដោយដាច់ខាតយ៉ាងដូចបព្វជិតមានភិក្ខុសាមណេរជាដើម។ តាមលទ្ធិបុរាណសំដៅយកកុមារឬកុមារីដែលនៅលីវសុទ្ធសាធ; ខាងលទ្ធិខ្មែរដែលប្រើតាមទម្លាប់ច្រើនតែសំដៅយកកុមារីជំទង់ហៅថា ស្ត្រីព្រហ្មចារី; តែបើតាមបែបត្រឹមត្រូវ :

- ព្រហ្មចារិនី សម្រាប់ហៅស្ត្រី។
- ព្រហ្មចារី សម្រាប់ហៅបុរស។

អព្រហ្មចារី ន. (ឃ.) អ្នកដែលមិនមែនជាព្រហ្មចារី។

📖 **ព្រហ្មចារ្យ ពាក្យផ្ទុយ អព្រហ្មចារ្យ**

ព្រហ្មចារ្យ ន. (**សំ.ក្ល.**) បែបបទរបស់ព្រហ្មចារីឬព្រហ្មចារិនី, សណ្ដាប់ធ្នាប់របស់ព្រហ្មចារីឬព្រហ្មចារិនី; ការប្រព្រឹត្តធម៌ដ៏ប្រសើរ។ តាមន័យខាងពុទ្ធសាសនាថា ការឱ្យទាន, ការខ្វល់ខ្វាយ, ការខ្នះខ្នែងចំពោះអំពើជាកុសល, ការរក្សាសីល៥, ការចម្រើនព្រហ្មវិហារ៤ ការសម្ដែងធម៌ឬណែនាំពន្យល់ឱ្យអ្នកដទៃកាន់អំពើសុចរិត, ការវៀរចាកមេថុនធម្ម, សេចក្ដីសន្ដោសចំពោះភរិយារបស់ខ្លួន, សេចក្ដីព្យាយាមដ៏ខ្ជាប់ខ្ជួនក្នុងការកុសល, ការរក្សាឧបោសថសីលតាមកាលកំណត់, អរិយមគ្គ, ព្រះពុទ្ធសាសនាទាំងមូល, អធ្យាស្រ័យ (ទាំង១២យ៉ាងនេះ) ហៅថា ព្រហ្មចារ្យ (ហៅថា ព្រហ្មចរិយធម៌ ក៏បាន)។

អព្រហ្មចារ្យ ន. (**ឯ.**) ការមិនប្រព្រឹត្តព្រហ្មចារ្យ (ហៅ អព្រហ្មចរិយធម៌ ក៏បាន)។

ព្រឹក

ពាក្យផ្ទុយ **ល្ងាច**

ព្រឹក ន. វេលាចាប់តាំងពីព្រះអាទិត្យបំព្រាងដល់ថ្ងៃពេញពន្លឺធំ; ដរាបដល់ថ្ងៃត្រង់ក៏នៅហៅ ព្រឹក បានដែរ។

ល្ងាច ន. វេលាដែលព្រះអាទិត្យទោរទាបចុះ :

❖ ធ្វើការតាំងពីព្រឹកដល់ល្ងាច។

ច្បាចារ

ពាក្យផ្ទុយ **អ្នកចារ**

ព្រៃឧសភ ៥. ជនជាតិវេស្សៈឬវៃស្យៈ (ក្នុងកម្ពុជប្រទេសមានតែក្នុងរជ្ជកាលអំពីដើម)។

អ្នកឧសភ ៥. អ្នកធ្វើការងារមានកម្រិតតាមរាជប្បញ្ញត្តិ គឺជនដែលត្រូវទោសរបឹបជាដើមហើយធ្លាក់ខ្លួនទៅជាមនុស្សថ្នាក់ទី៤ (សូទ្រៈ) ជាប់ជាពូជវង្សតរៀងទៅឬជនដែលកើតក្នុងពូជវង្សនោះ :

- ❖ ពួកអ្នកងារ
- ❖ ពូជអ្នកងារ។

☞ ក្នុងកម្ពុជរដ្ឋលើកលែងមិនឱ្យមានអ្នកងារពីក្នុងឆ្នាំរោង ចត្វាស័ក ព.ស.២៤៣៦ គ.ស.១៨៩២; តាំងពីនោះមកពាក្យថា អ្នកឧសភ ថា ព្រៃឧសភ ក៏បាត់បន្តិចម្តងៗដរាបមកដល់សម័យបច្ចុប្បន្ននេះ។

📖 **តព្វ** **ពាក្យផ្ទុយ** **អតព្វ**

តព្វ *ន.* (ឯ.) ភព្យ, ដែលគួរ, ដែលគួរដល់កិច្ចការ; ដែលមានសំណាងល្អ, ដែលមានសេចក្តីសុខ។

អតព្វ *ន.* (ឯ.) អភព្យ, ដែលមិនគួរ, ដែលពុំគួរដល់កិច្ចការ, ដែលពុំអាច; ដែលឥតសំណាងល្អ, ដែលមានសំណាងតិច; ដែលឃ្លាងចាកប្រយោជន៍, ដែលឃ្លាងចាកមគ្គផល។

📖 តព្វបុគ្គល ពាក្យផ្ទុយ អតព្វបុគ្គល

តព្វបុគ្គល *ន.* (ឥ.) បុគ្គលដែលមានសំណាងល្អ; បុគ្គលដែលគួរបួសជាបព្វជិតក្នុងព្រះពុទ្ធសាសនាបាន។

អតព្វបុគ្គល *ន.* (ឥ.) បុគ្គលអភព្វ។ បុគ្គលដែលមិនគួរបួសក្នុងព្រះពុទ្ធសាសនាបាន (ព.វិ.ពុ.)។

📖 តព្វរូប ពាក្យផ្ទុយ អតព្វរូប

តព្វរូប *នុ.* (ឥ.) ដែលមានសភាពដ៏សមគួរ។

អតព្វរូប *ន.* (ឥ.) សភាពពុំសមគួរ; ដែលមានសភាពពុំសមគួរ; ការឃ្លាងចាកប្រយោជន៍, ការឃ្លាងចាកលាភ; សេចក្តីទុក្ខ។

📖 តាព ពាក្យផ្ទុយ អតាព

តាព *ន.* (ឥ.សំ.ភ្ហ.) ភាវៈ; បែប, បែបបទ; លំនាំ, លំនាំសមសា, ឫកពា; ទម្រង់, សណ្ឋាន, ទ្រង់ទ្រាយ; ភេទ :

- ❖ ភាពល្អ
- ❖ ភាពអាក្រក់
- ❖ ភាពត្រឹមត្រូវ។

អតាព *ន.* (ឥ.សំ.ភ្ហ.) ការឥតភាព; ការមិនមាន; សេចក្តីស្លាប់។

📖 **ភូត** **ពាក្យផ្សំ** **សម្ភវេសី**

ភូត *ន.* (ប.ស.) អ្វីដែលកើតមានហើយ; ទេវតា; សត្វលោក; ខ្មោចបិសាច; បញ្ចក្ខន្ធ; ធាតុទាំងបួន; សេចក្តីពិត។

សម្ភវេសី *ន.* (ឯ.) អ្នករកដំណើរកើត គឺសត្វដែលនៅក្នុងគភ៌ឬនៅក្នុងស្រោមស៊ុតបម្រុងនឹងសម្រាលឬញាស់តាមកាលកំណត់ (ចំពោះ ជលុជៈ និង អណ្ឌជៈ); សត្វដែលផ្តើមចាប់កំណើតក្នុងខណៈចិត្តទី១ឬដែលផ្តើមចាប់កំណើតឡើងដោយឥរិយាបថណានៅមិនទាន់ផ្លាស់ឥរិយាបថនោះ (ចំពោះ សំសេទជៈ និង ឧបបាតិកៈ); សត្វដែលកំពុងស្វែងរកទីកើតតទៅទៀត (និយាយដោយរួបរួម); បើស្ត្រីជា សម្ភវេសិនី (តែមិនសូវប្រើ)។

📖 **តេជ្ជរូប** **ពាក្យផ្សំ** **អតេជ្ជរូប**

តេជ្ជរូប *នុ.* ឬ *ន.* (ឯ.) ដែលមានសភាពឆាប់ផ្តុះផ្តាយ, ឆាប់បែក, ដែលមិនជាប់បានយូរ, ឆាប់ខូច, មិនជាស្តាពរ :

❖ របស់តេជ្ជរូប។

អតេជ្ជរូប *នុ.* ឬ *ន.* (ឯ.) ដែលមានសភាពរឹងប៉ឹង, មាំ, ជាប់បានយូរ, មិនងាយផ្តុះផ្តាយ, ជាស្តាពរ :

❖ របស់អតេជ្ជរូប។

📖 **ស្ពឹក** ពាក្យថ្មុំយ **ស្ត**

ស្ពឹក *ន.* អវយវៈជាឆ្អឹងដុះចេញពីក្នុងមាត់ដំរីឈ្មោលមានសណ្ឋានមូលធំ ចុងស្រួចកាលណាលូតវែងមានទ្រង់ទ្រាយងងទន្មាំ, តាមធម្មតាតែងតែដុះចេញមកមួយគូ, ប៉ុន្តែច្រណាដុះទោលតែមួយក៏មានខ្លះហៅថា ស្ពឹកឯក។ ដំរីឈ្មោលដែលដុះភ្ពុកពីកំណើតគេមិនហៅ ឈ្មោល ទេគេហៅ ស្ពឹក :

❖ ហ្នដំរីខ្លះទាក់បានភ្ពុក ខ្លះទាក់បានស្ត (បើញីគេហៅ មេ គេមិនហៅ ញី ទេ)។

ស្ត *ន.* ដំរីឈ្មោលឥតភ្ពុកមានតែចែ, បើដំរីឈ្មោលឥតភ្ពុកឥតចែហៅ គោគ។

📖 **មង្គល** ពាក្យថ្មុំយ **អបមង្គល, អពមង្គល**

មង្គល *ន.* (ប.សំ.) សេចក្តីចម្រើន; សេចក្តីសុខ; ហេតុដែលនាំឱ្យកើតសេចក្តីសុខចម្រើន; ស្រីសួស្តី។

អបមង្គល *នុ.* (ប.សំ.) ដែលប្រាសចាកមង្គល, ដែលឃ្លាងចាកមង្គល គឺដែលឥតមង្គល, ដែលឥតសេចក្តីចម្រើន; ដែលមិនសមដល់ភ្នែកអ្នកផង; ដែលត្រូវចង្រៃរួមរឹត។

អពមង្គល *ន.* (ប.សំ.ក្ល.) សេចក្តីមិនចម្រើន; ហេតុដែលនាំឱ្យវិនាស, ហេតុដែលនាំឱ្យអាប់ឱន។

📖 **មហោថេរ ពាក្យផ្គុំ អនុត្ថេរ**

មហោថេរ *ន.* (ឋា.) ថេរៈធំ, ព្រះថេរៈធំ។ បើភិក្ខុនីជាមហាថេរី “ថេរីធំ”។

អនុត្ថេរ *ន.* (ឋា.) ថេរៈបន្ទាប់, ថេរៈតូច។

📖 **មហិច្ឆតា ពាក្យផ្គុំ អប្បិច្ឆតា**

មហិច្ឆតា *ន.* (ឋា.) សេចក្តីប្រាថ្នាធំ, ការចង់បានច្រើន, សេចក្តីលោភលន់ :

❖ មហិច្ឆតាជាធម្មជាតិនាំឱ្យមានការច្រណែនឈ្នានីសចំពោះគ្នីគ្នា។

អប្បិច្ឆតា *ន.* (ឋា.) បែបបទនៃអ្នកដែលមានសេចក្តីប្រាថ្នាតិច :

❖ ចិញ្ចឹមជីវិតដោយអប្បិច្ឆតា។

📖 **មហិច្ឆតាឍ ពាក្យផ្គុំ អប្បិច្ឆតាឍ**

មហិច្ឆតាឍ *ន.* (ឋា.ក្ល.) សេចក្តីប្រាថ្នាធំ, ការចង់បានច្រើន, សេចក្តីលោភលន់ :

❖ មហិច្ឆភាពជាធម្មជាតិនាំឱ្យមានការច្រណែនឈ្នានីសចំពោះគ្នីគ្នា។

អប្បិច្ឆតាឍ *ន.* (ឋា.ក្ល.) បែបបទនៃអ្នកដែលមានសេចក្តីប្រាថ្នាតិច :

❖ ចិញ្ចឹមជីវិតដោយអប្បិច្ឆភាព។

📖 **មហេសក្ខ ពាក្យផ្គុំ អប្បេសក្ខ**

មហេសក្ខ *នុ.* ឬ *ន.* (ឋា.) ពាក្យសម្រាប់ហៅទេវតាដែលមានអានុភាពធំ;

ក្នុងកាព្យប្រើជា មហេសក្ខ៑ ក៏បាន។

អប្បេសក្ខ *គុ.* (ឃ.) ដែលមានអំណាចតិច, ដែលខ្សោយអំណាចជាងគេ, ដែលតូចជាងគេ។

📖 មានពុត ពាក្យផ្ទុយ ស្លូតត្រង់

មានពុត *គុ.* ដែលមានចិត្តរបិញ្ជរបុញ្ជ។

ស្លូតត្រង់ *គុ.* ស្លូតផងត្រង់ផង។

📖 មានព្រលឹង ពាក្យផ្ទុយ មិនសូវមានព្រលឹង

មានព្រលឹង *គុ.* មានសាច់, ធាត់។

មិនសូវមានព្រលឹង *គុ.* មិនសូវមានសាច់, ស្គម។

📖 មិច្ឆា ពាក្យផ្ទុយ សម្មា

មិច្ឆា *អ.ន.* ឬ *គុ.* (ឃ.) ខុស, មិនពិត, មិនមែន។

សម្មា *ន.* (ឃ.) ប្រពៃ, ពិត, មែន, ត្រូវ, ត្រឹមត្រូវ។

📖 មិច្ឆាកម្មន្តៈ ពាក្យផ្ទុយ សម្មាកម្មន្តៈ

មិច្ឆាកម្មន្តៈ *ន.* (ឃ.ក្ត.) ការងារខុស។

សម្មាកម្មន្តៈ *ន.* (ឃ.ក្ត.) ការងារត្រូវ។

📖 មិច្ឆាចារ ពាក្យផ្ទុយ សម្មាចារ

មិច្ឆាចារ *ន.* (ឃ.) ដំណើរប្រព្រឹត្តទាស់ខុសប្រពៃណី; មារយាទអាក្រក់។

សម្មាចារ *ន.* (ឃ.) ការកាន់ត្រូវ; មារយាទត្រឹមត្រូវ; មារយាទល្អ។

📖 មិច្ឆាជីព ពាក្យផ្ទុយ សម្មាជីព

មិច្ឆាជីព *ន.* (ឃ.ក្ត.) ការចិញ្ចឹមជីវិតខុស។

សម្មាជីព *ន.* (ឃ.ក្ត.) ការចិញ្ចឹមជីវិតត្រូវ។

📖 មិច្ឆាជីវ ពាក្យផ្ទុយ សម្មាជីវ

មិច្ឆាជីវ *ន.* (ឃ.) ការចិញ្ចឹមជីវិតខុស។

សម្មាជីវ *ន.* (ឃ.) ការចិញ្ចឹមជីវិតត្រូវ។

📖 មិច្ឆាជីវៈ ពាក្យផ្ទុយ សម្មាជីវៈ

មិច្ឆាជីវៈ *ន.* (ឃ.ក្ត.) ការចិញ្ចឹមជីវិតខុស។

សម្មាជីវៈ *ន.* (ឃ.ក្ត.) ការចិញ្ចឹមជីវិតត្រូវ។

📖 មិច្ឆារជីវ ពាក្យផ្ទុយ សម្មារជីវ

មិច្ឆារជីវ *ន.* (ឃ.) ការចិញ្ចឹមជីវិតខុស។

សម្មារជីវ *ន.* (ឃ.) ការចិញ្ចឹមជីវិតត្រូវ។

📖 មិច្ឆារជីវោ ពាក្យផ្ទុយ សម្មារជីវោ

មិច្ឆារជីវោ *ន.* (ឃ.) ការចិញ្ចឹមជីវិតខុស។

សម្មារជីវោ *ន.* (ឃ.) ការចិញ្ចឹមជីវិតត្រូវ។

📖 មិច្ឆាទស្សនៈ ពាក្យផ្ទុយ សម្មាទស្សនៈ

មិច្ឆាទស្សនៈ *ន.* (ឋា.ភ្ជ.) ការយល់ឃើញខុស។

សម្មាទស្សនៈ *ន.* (ឋា.ភ្ជ.) ការយល់ឃើញត្រូវ។

📖 មិច្ឆាទិដ្ឋិ ពាក្យផ្ទុយ សម្មាទិដ្ឋិ

មិច្ឆាទិដ្ឋិ *ន.* (ឋា.) សេចក្តីយល់ឃើញខុស គឺដំណើរយល់ខុសអំពីសេចក្តីពិត ដូចយ៉ាងយល់ឃើញថា មាតាបិតាគ្មានគុណ, សត្វទាំងអស់ស្លាប់ហើយរលែងកើតទៀតជាដើម។

សម្មាទិដ្ឋិ *ន.* (ឋា.) សេចក្តីយល់ឃើញត្រូវ។

📖 មិច្ឆាបដិបត្តិ ពាក្យផ្ទុយ សម្មាបដិបត្តិ

មិច្ឆាបដិបត្តិ *ន.* (ឋា.) ការប្រតិបត្តិខុស។

សម្មាបដិបត្តិ *ន.* (ឋា.) ការប្រតិបត្តិត្រូវ។

📖 មិច្ឆាពាក្យ ពាក្យផ្ទុយ សម្មាពាក្យ

មិច្ឆាពាក្យ *ន.* (ឋា.ភ្ជ.) សម្តីខុស គឺការប្រើវាចាខុសគន្លងមានពោលពាក្យកុហក, ពាក្យញុះញង់ជាដើម។

សម្មាពាក្យ *ន.* (ឋា.) សម្តីត្រូវ។

📖 មិច្ឆាព្យាយាម ពាក្យផ្ទុយ សម្មាព្យាយាម

មិច្ឆាព្យាយាម *ន.* (ឥ. និង *សំ.ភ្ន.*) ព្យាយាមខុស គឺព្យាយាមធ្វើអំពើអាក្រក់។

សម្មាព្យាយាម *ន.* (ឥ. និង *សំ.ភ្ន.*) ព្យាយាមត្រូវគឺព្យាយាមធ្វើអំពើល្អ។

📖 **មិច្ឆាមគ្គ** **ពាក្យផ្ទុយ** **សម្មាមគ្គ**

មិច្ឆាមគ្គ *ន.* (ឥ.) ផ្លូវខុស គឺផ្លូវដែលមិនពិត, គន្លងដែលមិនពិត។

សម្មាមគ្គ *ន.* (ឥ.) ផ្លូវត្រូវ, គន្លងត្រូវ, លំអានត្រូវ។

📖 **មិច្ឆាវាចា** **ពាក្យផ្ទុយ** **សម្មាវាចា**

មិច្ឆាវាចា *ន.* (ឥ.) សម្ដីខុស គឺការប្រើវាចាខុសគន្លងមានពោលពាក្យកុហក, ពាក្យញុះញង់ជាដើម។

សម្មាវាចា *ន.* (ឥ.) សម្ដីត្រូវ គឺការប្រើវាចាត្រូវគន្លងមានពោលពាក្យមិនកុហក, ពាក្យមិនញុះញង់ជាដើម។

📖 **មិច្ឆាសង្កប្បៈ** **ពាក្យផ្ទុយ** **សម្មាសង្កប្បៈ**

មិច្ឆាសង្កប្បៈ *ន.* (ឥ.ភ្ន.) សេចក្ដីត្រិះរិះខុស, តម្រិះខុស។

សម្មាសង្កប្បៈ *ន.* (ឥ.ភ្ន.) សេចក្ដីត្រិះរិះត្រូវ, តម្រិះត្រូវ។

📖 **មិច្ឆាសតិ** **ពាក្យផ្ទុយ** **សម្មាសតិ**

មិច្ឆាសតិ *ន.* (ឥ.) សតិខុស, ការរលឹកខុស។

សម្មាសតិ *ន.* (ឥ.) សតិត្រូវ, ការរលឹកត្រូវ។

📖 មិច្ឆាសមាធិ ពាក្យផ្ទុយ សម្មាសមាធិ

មិច្ឆាសមាធិ *ន.* (**ឃ.**) សមាធិខុស។

សម្មាសមាធិ *ន.* (**ឃ.**) សមាធិត្រូវ។

📖 មិត្ត ពាក្យផ្ទុយ អមិត្ត

មិត្ត *ន.* (**ឃ.**) អ្នកដែលរាប់អានគ្នាជិតជិត, មនុស្សដែលស្រលាញ់រាប់រកគ្នាយ៉ាងជិតស្និទ្ធ, សម្លាញ់។

អមិត្ត *ន.* (**ឃ.**) អ្នកដែលមិនមែនជាមិត្ត (សត្រូវ)។

📖 មិត្តភាព ពាក្យផ្ទុយ អមិត្តភាព

មិត្តភាព *ន.* (**ឃ.ក្ល.**) ភាពនៃមិត្ត គឺបែបបទសណ្ដាប់ធ្នាប់របស់មិត្ត :

❖ រាប់អានគ្នាដោយមិត្តភាព។

អមិត្តភាព *ន.* (**ឃ.ក្ល.**) ភាពនៃបុគ្គលមិនមែនជាមិត្ត, ភាពនៃជនជាសត្រូវ, ការដែលជាខ្មាំងសត្រូវនឹងគ្នា, ទោសសត្រូវ។

📖 មិត្រ ពាក្យផ្ទុយ អមិត្រ

មិត្រ *ន.* (**សំ.**) អ្នកដែលរាប់អានគ្នាជិតជិត, មនុស្សដែលស្រលាញ់រាប់រកគ្នាយ៉ាងជិតស្និទ្ធ, សម្លាញ់។

អមិត្រ *ន.* (**សំ.**) អ្នកដែលមិនមែនជាមិត្រ (សត្រូវ)។

📖 **មោឃៈ** **ពាក្យផ្ទុយ** **អមោឃៈ**

មោឃៈ *នុ.* (**ឥ.សំ.**) ដែលសោះសូន្យ, ដែលឥតប្រយោជន៍, ដែលអសារឥតការ, ដែលអសារឥតអំពើ; ទទេ, ឃៃត, ចោលម្បៀត។

អមោឃៈ *នុ.* (**ឥ.សំ.**) ដែលមិនមែនទទេ, ដែលមិនសោះសូន្យ, ដែលមិនឥតប្រយោជន៍, ដែលមិនឥតអំពើ គឺកើតការ, បានការ, មានប្រយោជន៍។

📖 **មោហៈ** **ពាក្យផ្ទុយ** **អមោហៈ**

មោហៈ *ន.* (**ឥ.សំ.ក្ល.**) អវិជ្ជា, សេចក្តីវង្វេង, សេចក្តីល្ងង់, សេចក្តីភន្តស្មារតីមិនយល់ការណ៍ពិត, សេចក្តីមិនស្គាល់ខុសត្រូវ។

អមោហៈ *ន.* (**ឥ.សំ.ក្ល.**) ការមិនវង្វេងស្មារតី, ការមិនភន្តច្រលំ, សេចក្តីដឹង; ការស្គាល់ខុសត្រូវ; ប្រីជា, ប្រាជ្ញា។

📖 **មោហោ** **ពាក្យផ្ទុយ** **អមោហោ**

មោហោ *ន.* (**ឥ.សំ.**) អវិជ្ជា, សេចក្តីវង្វេង, សេចក្តីល្ងង់, សេចក្តីភន្តស្មារតីមិនយល់ការណ៍ពិត, ការមិនស្គាល់ខុសត្រូវ។

អមោហោ *ន.* (**ឥ.សំ.**) ការមិនវង្វេងស្មារតី, ការមិនភន្តច្រលំ, សេចក្តីដឹង; ការស្គាល់ខុសត្រូវ។

📖 **ម្តាយមាន់** **ពាក្យផ្ទុយ** **ម្តាយអណ្តើក**

ម្តាយមាន់ *ន.* ម្តាយដូចជាមេមាន់។

ម្តាយរណ្តើក *ន.* ម្តាយណាដែលគ្រាន់តែបង្កើតកូនមកហើយក៏បោះបង់ចោលមិនបីបាច់រក្សា, អ្នកប្រាជ្ញលោកពោលដោយឧបមាថា ម្តាយនោះឯងដូចជាមេអណ្តើកដែលគ្រាន់តែបញ្ចេញស៊ុតហើយ ក៏កកាយដីលុបកប់ស៊ុតហើយបោះបង់ចោលឥតនឹកនាដូច្នោះដែរ; លទ្ធិពុទ្ធពោលថា ទោះបីយ៉ាងនេះក៏ដោយមាតានោះក៏ឈ្មោះថាជា ម្តាយនៃកូននោះហើយ, កាលបើកូននោះបានស្គាល់ថាជាម្តាយបង្កើតរបស់ខ្លួនក៏ត្រូវតែកូននោះជា កតវេទិ ឬ កតវេទិនី ចំពោះម្តាយនោះដែរ។

📖 **យស** **ពាក្យផ្ទុយ** **អយស**

យស *ន.* (**ឥ.សំ.**) អានុភាព; ឥស្សរភាព; បរិវារ; ទ្រព្យធន; កេរ្តិ៍ឈ្មោះល្អ; សេចក្តីថ្កើងថ្កាន។

អយស *ន.* (**ឥ.សំ.**) គ្មានអានុភាព; គ្មានឥស្សរភាព; គ្មានបរិវារ; គ្មានទ្រព្យធន; គ្មានកេរ្តិ៍ឈ្មោះល្អ; គ្មានសេចក្តីថ្កើងថ្កាន។

📖 **យុត្តិធម៌** **ពាក្យផ្ទុយ** **អយុត្តិធម៌**

យុត្តិធម៌ *ន.* (**ឥ.** និង **សំ.**) ធម៌ដែលគួរកាន់; សេចក្តីទៀងត្រង់; ការប្រព្រឹត្តត្រឹមត្រូវ :

❖ វិនិច្ឆ័យក្តីដោយយុត្តិធម៌។

អយុត្តិធម៌ *ន.* (ឃ. និង *សំ.*) សភាពមានដំណើរខុសធម៌, សភាពមានដំណើរខុសច្បាប់, ការប្រព្រឹត្តពុំត្រឹមត្រូវតាមគន្លងធម៌, ការប្រព្រឹត្តពុំត្រឹមត្រូវតាមគន្លងច្បាប់ :

❖ ចៅក្រមវិនិច្ឆ័យក្តីដោយអយុត្តិធម៌។

📖 យុវជន ពាក្យផ្ទុយ វយជន

យុវជន *ន.* (ឃ.) ជនកំលោះ; ជនកំលោះក្រមុំ។

វយជន *ន.* (ឃ.) ជនចាស់។

📖 យោគិន ពាក្យផ្ទុយ អយោគិន

យោគិន *ន.* (*សំ.*) អ្នកមានព្យាយាមខាងការភាវនា, អ្នកមានព្យាយាមខាងការស្ងៀងស្ងាត់, អ្នកចម្រើនកម្មដ្ឋាន; បព្វជិត; តាបស, ឥសី។

អយោគិន *ន.* (*សំ.*) អ្នកដែលមិនមែនជាយោគិន។

📖 យោគិនី ពាក្យផ្ទុយ អយោគិនី

យោគិនី *ន.* (ឃ.) ស្ត្រីអ្នកមានព្យាយាមខាងការភាវនា, ស្ត្រីអ្នកមានព្យាយាមខាងការស្ងៀងស្ងាត់, ស្ត្រីអ្នកចម្រើនកម្មដ្ឋាន។

អយោគិនី *ន.* (ឃ.) ស្ត្រីអ្នកដែលមិនមែនជាយោគិនី។

📖 **យោគី** **ពាក្យផ្គុំ** **អយោគី**

យោគី *ន.* (ឋា.) អ្នកមានព្យាយាមខាងការភាវនា, អ្នកមានព្យាយាមខាងការស្ងៀងស្ងាត់, អ្នកចម្រើនកម្មដ្ឋាន; បព្វជិត; តាបស, ឥសី។

អយោគី *ន.* (ឋា.) អ្នកដែលមិនមែនជាយោគី។

📖 **យោធ** **ពាក្យផ្គុំ** **អយោធ**

យោធ *ន.* (ឋា.សំ.) អ្នកចម្បាំង, ទាហាន។

អយោធ *ន.* (ឋា.សំ.) អ្នកដែលមិនមែនជាយោធា, មនុស្សក្រៅពីទាហាន។

📖 **យោធា** **ពាក្យផ្គុំ** **អយោធា**

យោធា *ន.* ទាហានទាំងឡាយ, ពួកទាហាន។

អយោធា *ន.* (ឋា.សំ.) អ្នកដែលមិនមែនជាយោធា, មនុស្សក្រៅពីទាហាន។

📖 **យោធិន** **ពាក្យផ្គុំ** **អយោធិន**

យោធិន *ន.* (សំ.) អ្នកច្បាំង, ទាហាន។

អយោធិន *ន.* (សំ.) អ្នកដែលមិនមែនជាយោធា, មនុស្សក្រៅពីទាហាន។

📖 **យោនិសោមនសិការ** **ពាក្យផ្គុំ** **អយោនិសោមនសិការ**

យោនិសោមនសិការ *ន.* (ឋា.) ការពិចារណាដោយឧបាយទៀងទាត់, ការពិចារណាដោយគំនិតទៀងទាត់; ដំណើរយកចិត្តទុកដាក់; សេចក្តីគិត

ត្រូវទំនង។

អយោនិសោមនសិការ *ន.* (**ឃ.**) ការមិនពិចារណាដោយឧបាយ, ការមិនពិចារណាដោយគំនិតទៀងទាត់, ការមិនពិចារណាដោយគំនិតល្អិតល្អន; ដំណើរមិនយកចិត្តទុកដាក់, ការគិតខុសទំនង; ការឥតបើគិត។

📖 រស់ ពាក្យផ្ទុយ ស្លាប់

រស់ *ភិ.* មានជីវិតនៅ, មិនទាន់ស្លាប់។

ស្លាប់ *ភិ.* អស់ខ្យល់ដង្ហើម, អស់ជីវិត។

📖 រាជទ្រព្យ ពាក្យផ្ទុយ រាជ្យទ្រព្យ

រាជទ្រព្យ *ន.* (**ឃ.** និង **សំ.ក្ល.**) ទ្រព្យរបស់ព្រះរាជា មិនមែនសម្រាប់រាជ្យ។

រាជ្យទ្រព្យ *ន.* (**សំ.** និង **សំ.ក្ល.**) ទ្រព្យសម្រាប់រាជ្យ, របស់រាជការ។

📖 រាត្រីសុខស្ដិ! ពាក្យផ្ទុយ សាយណ្ហសុខស្ដិ!, អរុណសុខស្ដិ!

រាត្រីសុខស្ដិ! *ន.* សួស្ដីក្នុងវេលាយប់; ពាក្យសម្រាប់ឱ្យពរគ្នាក្នុងវេលាយប់ (ប្រើតាមសម័យនិយម), បានសេចក្ដីថា សូមឱ្យមានសួស្ដីក្នុងវេលាយប់!។

សាយណ្ហសុខស្ដិ! *ន.* សួស្ដីក្នុងវេលាល្ងាច; ពាក្យសម្រាប់ឱ្យពរគ្នាក្នុងវេលាតាំងពីថ្ងៃត្រង់រហូតដល់ថ្ងៃល្ងាច (ប្រើតាមសម័យនិយម), បានសេចក្ដីថា សូមឱ្យមានសួស្ដីក្នុងវេលាល្ងាច!។

អរុណាសុវត្ថិ! *ន.* សួស្តីក្នុងវេលាព្រឹក; ពាក្យសម្រាប់ឱ្យពរគ្នាក្នុងវេលាតាំងពីព្រហាមរហូតដល់ថ្ងៃត្រង់ (ប្រើតាមសម័យនិយម), បានសេចក្តីថា សូមឱ្យមានសួស្តីក្នុងវេលាព្រឹក!។

📖 រាត្រីសួស្តី! ពាក្យផ្ទុយ សាយណ្ហសួស្តី!, អរុណាសួស្តី!

រាត្រីសួស្តី! *ន.* សួស្តីក្នុងវេលាយប់; ពាក្យសម្រាប់ឱ្យពរគ្នាក្នុងវេលាយប់ (ប្រើតាមសម័យនិយម), បានសេចក្តីថា សូមឱ្យមានសួស្តីក្នុងវេលាយប់!។

សាយណ្ហសួស្តី! *ន.* សួស្តីក្នុងវេលាល្ងាច; ពាក្យសម្រាប់ឱ្យពរគ្នាក្នុងវេលាតាំងពីថ្ងៃត្រង់រហូតដល់ថ្ងៃល្ងាច (ប្រើតាមសម័យនិយម), បានសេចក្តីថា សូមឱ្យមានសួស្តីក្នុងវេលាល្ងាច!។

អរុណាសួស្តី! *ន.* សួស្តីក្នុងវេលាព្រឹក; ពាក្យសម្រាប់ឱ្យពរគ្នាឬគំនាប់គ្នាក្នុងវេលាតាំងពីព្រហាមរហូតដល់ថ្ងៃត្រង់ (ប្រើតាមសម័យនិយម), បានសេចក្តីថា សូមឱ្យមានសួស្តីក្នុងវេលាព្រឹក!។

📖 រាស្ត្រ ពាក្យផ្ទុយ ស្តេច

រាស្ត្រ *ន.* (*សំ.*) ដែន, ប្រទេស; អ្នកនៅក្នុងដែន, ប្រជាជន។ ខ្មែរប្រើពាក្យនេះសំដៅសេចក្តីថា “ប្រជាជនសម្រាប់ដែន (ក្រៅពីពួកក្សត្រនិងនាហ្លឹន)” :

❖ ពួករាស្ត្រ។

ស្ដេច *ន.* ក្សត្រ, អ្នកដែលកើតក្នុងវង្សក្សត្រ :

❖ ជាតិស្ដេច។

📖 រូបនាម ពាក្យផ្ទុយ អរូបនាម

រូបនាម *ន.* (ឯ.) រូបនិងនាម (ព.អ.)។ នាមនាមដែលមានរូបដូចយ៉ាង :

❖ ដី

❖ ទឹក

❖ សត្វ

❖ មនុស្ស។

អរូបនាម *ន.* (ព.វ.) នាមសព្ទដែលឥតរូប :

❖ ចិត្ត

❖ វិញ្ញាណ

❖ បំណង។

📖 រូបព្រហ្ម ពាក្យផ្ទុយ អរូបព្រហ្ម

រូបព្រហ្ម *ន.* (ឯ.) ព្រហ្មមានរូប, ព្រហ្មដែលកើតក្នុងរូបភព។

អរូបព្រហ្ម *ន.* (ឯ.) ព្រហ្មឥតរូប។

📖 រូបភព ពាក្យផ្ទុយ អរូបភព

រូបតាព *ន.* (**ឋា.ក្ត.**) កន្លែងកើតនៃព្រហ្ម។

អរូបតាព *ន.* (**ឋា.ក្ត.**) លោកជាទីនៅនៃអរូបព្រហ្ម។

📖 **រូបលោក** **ពាក្យផ្ទុយ** **អរូបលោក**

រូបលោក *ន.* (**ឋា.**) កន្លែងកើតនៃព្រហ្ម។

អរូបលោក *ន.* (**ឋា.**) លោកជាទីនៅនៃអរូបព្រហ្ម។

📖 **លក់ដុំ** **ពាក្យផ្ទុយ** **លក់រាយ**

លក់ដុំ *កិ.* លក់ទាំងដុំៗទីទៃពីលក់រាយ។

លក់រាយ *កិ.* លក់រាយៗតាមតែគេទិញអ្វីៗប៉ុន្មានៗក៏ដោយទីទៃពីលក់ដុំ។

📖 **លជ្ជាតាព** **ពាក្យផ្ទុយ** **អលជ្ជាតាព**

លជ្ជាតាព *ន.* (**ឋា.ក្ត.**) ភាវៈនៃសេចក្តីខ្មាស, ដំណើរអៀនខ្មាស :

❖ ចូលទៅរកគេដោយលជ្ជាភាព។

អលជ្ជាតាព *ន.* (**ឋា.ក្ត.**) ភាវៈនៃសេចក្តីឥតខ្មាស, ដំណើរឥតខ្មាស; ភាពជាអ្នកឥតខ្មាស :

❖ ប្រព្រឹត្តអនាចារដោយអលជ្ជាភាព។

📖 **លជ្ជិតា** **ពាក្យផ្ទុយ** **អលជ្ជិតា**

លជ្ជិតា *ន.* (**ឋា.**) ភាវៈនៃសេចក្តីខ្មាស, ដំណើរអៀនខ្មាស :

❖ ចូលទៅរកគេដោយលជ្ជិតា។

អលជ្ជិតា *ន.* (ឋា.) ភាវៈនៃសេចក្តីឥតខ្មាស, ដំណើរឥតខ្មាស; ភាពជាអ្នកឥតខ្មាស :

❖ ប្រព្រឹត្តអនាចារដោយអលជ្ជិតា។

📖 លជ្ជិនី ពាក្យផ្ទុយ អលជ្ជិនី

លជ្ជិនី *នុ.* ឬ *ន.* (ឋា.) ដែលមានសេចក្តីខ្មាស; ស្ត្រីអ្នកមានខ្មាស :

❖ មនុស្សលជ្ជិនី។

អលជ្ជិនី *នុ.* ឬ *ន.* (ឋា.) ដែលឥតខ្មាស; ស្ត្រីអ្នកឥតខ្មាស :

❖ មនុស្សអលជ្ជិនី។

📖 លជ្ជី ពាក្យផ្ទុយ អលជ្ជី

លជ្ជី *នុ.* ឬ *ន.* (ឋា.) ដែលមានសេចក្តីខ្មាស; អ្នកមានខ្មាស :

❖ មនុស្សលជ្ជី។

អលជ្ជី *នុ.* ឬ *ន.* (ឋា.) ដែលឥតខ្មាស; អ្នកឥតខ្មាស :

❖ មនុស្សអលជ្ជី។

📖 លជ្ជីបព្វជិត ពាក្យផ្ទុយ អលជ្ជីបព្វជិត

លជ្ជីបព្វជិត *ន.* (ឋា.) បព្វជិតមានខ្មាស។

អលជ្ជីបព្វជិត *ន.* (ឃ.) បព្វជិតឥតខ្មាស។

📖 **លជ្ជីបុគ្គល** **ពាក្យផ្ទុយ** **អលជ្ជីបុគ្គល**

លជ្ជីបុគ្គល *ន.* (ឃ.) បុគ្គលមានខ្មាស។

អលជ្ជីបុគ្គល *ន.* (ឃ.) បុគ្គលឥតខ្មាស។

📖 **លជ្ជីភាព** **ពាក្យផ្ទុយ** **អលជ្ជីភាព**

លជ្ជីភាព *ន.* (ឃ.ភ្ន.) ភាពរបស់អ្នកមានសេចក្តីខ្មាស, ដំណើររបស់អ្នកមានសេចក្តីខ្មាស។

អលជ្ជីភាព *ន.* (ឃ.ភ្ន.) ភាពរបស់អ្នកឥតខ្មាស, ដំណើររបស់អ្នកឥតខ្មាស។

📖 **លជ្ជីភិក្ខុ** **ពាក្យផ្ទុយ** **អលជ្ជីភិក្ខុ**

លជ្ជីភិក្ខុ *ន.* (ឃ.) ភិក្ខុមានខ្មាស។

អលជ្ជីភិក្ខុ *ន.* (ឃ.) ភិក្ខុឥតខ្មាស។

📖 **លជ្ជីសមណៈ** **ពាក្យផ្ទុយ** **អលជ្ជីសមណៈ**

លជ្ជីសមណៈ *ន.* (ឃ.ភ្ន.) សមណៈមានខ្មាស។

អលជ្ជីសមណៈ *ន.* (ឃ.ភ្ន.) សមណៈឥតខ្មាស។

📖 **លាភ** **ពាក្យផ្ទុយ** **អលាភ**

លាភ *ន.* (ឃ.សំ.) ការបាន, ដំណើរប្រទះលើការបាន, អ្វីៗដែលគួរបាន;

ចំណេញ :

❖ មានលាភ។

អលាភ *ន.* (ឥ.សំ.) ការឥតលាភ, ការខានបាន, ដំណើរប្រទះលើការខានបាន; ការខាតបង់ :

❖ ប្រទះលើអលាភ។

🕮 លិច ពាក្យផ្ទុយ អណ្តែត

លិច *កិ.* លិបចុះបាត់ទៅ, ធ្លុះកប់បាត់ទៅក្នុងទឹកជាដើម :

❖ ទូកលិច

❖ បន្លាមុតលិច។

អណ្តែត *កិ.* ឋិតនៅលើទឹក; រសាត់ឬលឿនលើទឹកដោយកម្លាំងខ្សែទឹក; រសាត់ឬលឿននាអាកាសដោយកម្លាំងខ្យល់ :

❖ ផ្តិលអណ្តែតទឹកក្នុងពាង

❖ ប៉ុយគរសាត់អណ្តែតទៅតាមខ្យល់។

🕮 លោកិយ ពាក្យផ្ទុយ លោកុត្តរ

លោកិយ *នុ.* (ឥ.) ដែលមានក្នុងលោក; ដែលជាប់ទាក់ទងដោយលោក; សម្រាប់លោក។

លោកុត្តរ *ន.* (ឯ.) ធម៌ចម្ដងសត្វឱ្យចេញផុតចាកលោក គឺមគ្គ៤, ផល៤, និព្វាន១; ហៅថា ឧត្ដរលោកុត្តរធម៌ ក៏បាន (ព.ពុ.)។

📖 លោភោ ពាក្យផ្ទុយ អលោភោ

លោភោ *គុ.* (ឯ.) ដែលចង់បានហួសពេក :

- ចិត្តលោភោ
- មនុស្សលោភោ។

អលោភោ *គុ.* (ឯ.) ដែលឥតលោភ, ដែលមិនសូវមានលោភ :

- ចិត្តអលោភោ
- មនុស្សអលោភោ។

📖 វឌ្ឍនៈ ពាក្យផ្ទុយ ហាយនៈ

វឌ្ឍនៈ *ន.* (ឯ.ក្ល.) សេចក្ដីចម្រើន; ការល្បួតលាស់; ដំណើរដុះដាល; ដំណើរកើតកាលវាលគុម្ព។

ហាយនៈ *ន.* (ឯ.ក្ល.) សេចក្ដីវិនាស, សេចក្ដីសាបសូន្យ; ដំណើរទ្រុឌទ្រោម។

📖 វឌ្ឍនតាតិនី ពាក្យផ្ទុយ ហានតាតិនី

វឌ្ឍនតាតិនី *គុ.* ឬ *ន.* (ឯ.) ដែលមានចំណែកខាងចម្រើន; ស្ត្រីអ្នកដែលមានចំណែកទៅខាងតែចម្រើន, ស្ត្រីអ្នកដែលចេះតែចម្រើន :

❖ មនុស្សប្រព្រឹត្តអំពើត្រង់ជាវឌ្ឍនភាគិនី។

ហានភាគិនី *គុ.* ឬ *ន.* (**ឆ.**) ដែលមានចំណែកខាងវិនាស; ស្ត្រីអ្នកដែលមានចំណែកទៅខាងតែវិនាស, ស្ត្រីអ្នកដែលចេះតែវិនាស :

❖ មនុស្សប្រព្រឹត្តអំពើវៀចជាហានភាគិនី។

📖 ឥឌ្ឍនភាគី ពាក្យផ្ទុយ ហានភាគី

ឥឌ្ឍនភាគី *គុ.* ឬ *ន.* (**ឆ.**) ដែលមានចំណែកខាងចម្រើន; អ្នកដែលមានចំណែកទៅខាងតែចម្រើន, អ្នកដែលចេះតែចម្រើន :

❖ មនុស្សប្រព្រឹត្តអំពើត្រង់ជាវឌ្ឍនភាគី។

ហានភាគី *គុ.* ឬ *ន.* (**ឆ.**) ដែលមានចំណែកខាងវិនាស; អ្នកដែលមានចំណែកទៅខាងតែវិនាស, អ្នកដែលចេះតែវិនាស :

❖ មនុស្សប្រព្រឹត្តអំពើវៀចជាហានភាគី។

📖 ឥន្ទ្រីយបុគ្គល ពាក្យផ្ទុយ អវន្ទ្រីយបុគ្គល

ឥន្ទ្រីយបុគ្គល *ន.* (**ឆ.**) បុគ្គលដែលគួរគេសំពះ :

❖ មាតាបិតាជាវន្ទ្រីយបុគ្គលរបស់បុត្រធីតា។

អវន្ទ្រីយបុគ្គល *ន.* (**ឆ.**) បុគ្គលដែលមិនគួរសំពះ :

❖ អវន្ទ្រីយបុគ្គល១០ចំពួកឬ២៥ចំពួកភិក្ខុពុំត្រូវសំពះឡើយ (ព.វិ.ពុ.)។

📖 **វាសរសេដ្ឋាតិវាទ ពាក្យផ្ទុយ សាយណ្ហាតិវាទ**

វាសរសេដ្ឋាតិវាទ *ន.* (ឋ.) ការពោលពាក្យគំនាប់គ្នាទៅវិញទៅមកក្នុងវេលាព្រឹក, ដូចជា :

❖ សុភស្តេប្រភាត! “វេលាព្រឹកដ៏ល្អចូរមានដល់អ្នក!”។

សាយណ្ហាតិវាទ *ន.* (ឋ.) ការពោលពាក្យគំនាប់គ្នាក្នុងវេលាសាយណ្ហថា :

❖ សាយណ្ហសុវត្ថិ! ឬសាយណ្ហសួស្តី!។

📖 **ខជ្ជមាន ពាក្យផ្ទុយ អខជ្ជមាន**

ខជ្ជមាន *នុ.* (ឋ.) ដែលកំពុងមាននៅឡើយ, ធរមាន។

អខជ្ជមាន *នុ.* (ឋ.) ដែលកំពុងតែមិនមាន, ដែលឥតមានសោះឡើយ។

📖 **ខជ្ជា ពាក្យផ្ទុយ អខជ្ជា**

ខជ្ជា *ន.* (ឋ.) សេចក្តីដឹងច្បាស់; ការចេះដឹង, ចំណេះ; វេទមន្ត, មន្តអាគម :

❖ វិជ្ជាលេខ

❖ វិជ្ជាពេទ្យ។

អខជ្ជា *ន.* (ឋ.) ការមិនដឹងច្បាស់, សេចក្តីល្ងង់, មោហៈ, មោហោ :

❖ សត្វលោកត្រូវអវិជ្ជារួបរឹតងងឹតភន្តច្រលំយល់ខុសថាជាត្រូវ។

📖 **ខញ្ញោឈរកន្ត្រៀ ពាក្យផ្ទុយ អខញ្ញោឈរកន្ត្រៀ**

ឥណ្ឌាឈរក្នុងព្យ *ន.* (ឥ. និង *សំ.ក្ត.*) ទ្រព្យមានវិញ្ញាណ :

❖ គោ

❖ ក្របី។

អឥណ្ឌាឈរក្នុងព្យ *ន.* (ឥ. និង *សំ.ក្ត.*) ទ្រព្យឥតវិញ្ញាណ :

❖ មាស

❖ ប្រាក់។

📖 **ឥណ្ឌូ** **ពាក្យផ្គុំ** **អឥណ្ឌូ**

ឥណ្ឌូ *ន.* (ឥ.) អ្នកដឹងច្បាស់, អ្នកដឹងហេតុផ្សេងៗ (ស្អែកជ្រាវ)។

អឥណ្ឌូ *នុ.* (ឥ.) ដែលមិនមានការដឹង; ល្ងង់, ខ្លៅ។

📖 **ឥណ្ឌូជន** **ពាក្យផ្គុំ** **អឥណ្ឌូជន**

ឥណ្ឌូជន *ន.* (ឥ.) អ្នកប្រាជ្ញ។

អឥណ្ឌូជន *ន.* (ឥ.) ជនល្ងង់, ជនខ្លៅ។

📖 **ឥណ្ឌូបុរស** **ពាក្យផ្គុំ** **អឥណ្ឌូបុរស**

ឥណ្ឌូបុរស *ន.* (ឥ.) អ្នកប្រាជ្ញ។

អឥណ្ឌូបុរស *ន.* (ឥ.) បុរសល្ងង់, បុរសខ្លៅ។

📖 **ឥណ្ឌូនេស** **ពាក្យផ្គុំ** **អឥណ្ឌូនេស**

ឥញ្ញាភាព *ន.* (ឃ.ភ្ន.) ភាពនៃវិញ្ញូ; ភាវៈនៃកូនក្មេងដឹងក្តី។

អឥញ្ញាភាព *ន.* (ឃ.ភ្ន.) ភាពនៃអវិញ្ញូ; ភាវៈនៃកូនក្មេងតូចពុំទាន់ដឹងក្តី។

📖 ឥទ្ធា ពាក្យផ្ទុយ អឥទ្ធា

ឥទ្ធា *ន.* (សំ.) សេចក្តីដឹងច្បាស់; ការចេះដឹង, ចំណេះ; វេទមន្ត, មន្តអាគម :

- ❖ វិទ្យាលេខ
- ❖ វិទ្យាពេទ្យ។

អឥទ្ធា *ន.* (សំ.) ការមិនដឹងច្បាស់, សេចក្តីល្ងង់, មោហៈឬមោហោ :

- ❖ សត្វលោកត្រូវអវិទ្យារួបរឹតងងឹតភន្តច្រលំយល់ខុសថាជាត្រូវ។

📖 ឥនយកថា ពាក្យផ្ទុយ អឥនយកថា

ឥនយកថា *ន.* (ឃ.) សម្តីប្រារព្ធវិន័យ, សម្តីអាងវិន័យ។

អឥនយកថា *ន.* (ឃ.) សម្តីខុសច្បាប់, សម្តីក្រៅច្បាប់។

📖 ឥនយសាចា ពាក្យផ្ទុយ អឥនយសាចា

ឥនយសាចា *ន.* (ឃ.) សម្តីត្រូវច្បាប់, សម្តីក្នុងច្បាប់។

អឥនយសាចា *ន.* (ឃ.) សម្តីខុសច្បាប់, សម្តីក្រៅច្បាប់។

📖 ឥនយសាឥ ពាក្យផ្ទុយ អឥនយសាឥ

ឥនយសាឥ *ន.* (ឃ.) ពាក្យពោលអាងវិន័យ។

អនឧបសាធ ន. (ឯ.) សម្តីខុសច្បាប់, សម្តីក្រៅច្បាប់។

📖 ឧឧបសាធិន ពាក្យផ្ទុយ អនឧបសាធិន

ឧឧបសាធិន ន. (សំ.) អ្នកពោលអាងវិន័យ, អ្នកនិយាយប្រកាន់តាមវិន័យ។

អនឧបសាធិន ន. (សំ.) អ្នកដែលច្រើនតែនិយាយខុសច្បាប់, អ្នកដែលច្រើនតែនិយាយក្រៅច្បាប់។

📖 ឧឧបសាធិនី ពាក្យផ្ទុយ អនឧបសាធិនី

ឧឧបសាធិនី ន. (ឯ.) ស្ត្រីអ្នកពោលអាងវិន័យ, ស្ត្រីអ្នកនិយាយប្រកាន់តាមវិន័យ។

អនឧបសាធិនី ន. (ឯ.) ស្ត្រីអ្នកដែលច្រើនតែនិយាយខុសច្បាប់, ស្ត្រីអ្នកដែលច្រើនតែនិយាយក្រៅច្បាប់។

📖 ឧឧបសាធី ពាក្យផ្ទុយ អនឧបសាធី

ឧឧបសាធី ន. (ឯ.) អ្នកពោលអាងវិន័យ, អ្នកនិយាយប្រកាន់តាមវិន័យ។

អនឧបសាធី ន. (ឯ.) អ្នកដែលច្រើនតែនិយាយខុសច្បាប់, អ្នកដែលច្រើនតែនិយាយក្រៅច្បាប់។

📖 ឧរុទ្ធ ពាក្យផ្ទុយ អឧរុទ្ធ

ឧរុទ្ធ ឬ. (ឯ.សំ.) ដែលខុស; ដែលទីទៃពីគ្នា, ដែលផ្ទុយគ្នា។

អនុរុទ្ធ *ន.* (ឥ.សំ.) ដែលមិនខុស, ដែលឥតខុស; ដែលឥតទាស់, ដែលឥតឆ្គង គឺត្រឹមត្រូវ; ស្រួល; ស្របគ្នា, ត្រូវគ្នា (ប្រើជា អពិរុទ្ធ ក៏បាន)។

📖 **ឥរុទ្ធកថា** **ពាក្យផ្ទុយ** **អនុរុទ្ធកថា**

ឥរុទ្ធកថា *ន.* (ឥ.សំ.) សម្តីមិនត្រឹមត្រូវ។

អនុរុទ្ធកថា *ន.* (ឥ.សំ.) សម្តីត្រឹមត្រូវ។

📖 **ឥរុទ្ធបាឋ** **ពាក្យផ្ទុយ** **អនុរុទ្ធបាឋ**

ឥរុទ្ធបាឋ *ន.* (ឥ.សំ.) បាលីខុស។

អនុរុទ្ធបាឋ *ន.* (ឥ.សំ.) បាលីត្រឹមត្រូវ។

📖 **ឥរុទ្ធភាព** **ពាក្យផ្ទុយ** **អនុរុទ្ធភាព**

ឥរុទ្ធភាព *ន.* (ឥ.សំ.ភ្ន.) ភាពមិនត្រឹមត្រូវ; ភាពឆ្គង។

អនុរុទ្ធភាព *ន.* (ឥ.សំ.ភ្ន.) ភាពត្រឹមត្រូវ; ភាពឥតឆ្គង។

📖 **ឥរុទ្ធភាសា** **ពាក្យផ្ទុយ** **អនុរុទ្ធភាសា**

ឥរុទ្ធភាសា *ន.* (ឥ.សំ.) សម្តីខុស។

អនុរុទ្ធភាសា *ន.* (ឥ.សំ.) សម្តីត្រឹមត្រូវ។

📖 **ឥរុទ្ធភាវ** **ពាក្យផ្ទុយ** **អនុរុទ្ធភាវ**

ឥរុទ្ធភាវ *ន.* (ឥ.សំ.) សម្តីខុស, ពំនោលខុស។

អនុរុទ្ធវាទ *ន.* (ឥ.សំ.) សម្តីត្រឹមត្រូវ, ពំនោលត្រឹមត្រូវ។

📖 **ទុរុទ្ធសព្ទ** **ពាក្យផ្ទុយ** **អនុរុទ្ធសព្ទ**

ទុរុទ្ធសព្ទ *ន.* (សំ.) សព្ទខុស; សព្ទផ្ទុយគ្នា។

អនុរុទ្ធសព្ទ *ន.* (សំ.) សព្ទត្រឹមត្រូវ; សព្ទស្របគ្នា។

📖 **ទរូប** **ពាក្យផ្ទុយ** **សរូប**

ទរូប *នុ.* ឬ *ន.* (ឥ.សំ.) រូបអាក្រក់; ដែលមានរូបអាក្រក់ប្លែក; ដែលអាក្រក់, គួរខ្ពើម; ពិការ។

សរូប *នុ.* ឬ *ន.* (ឥ.សំ.) រូបល្អ; ដែលមានរូបល្អ។

📖 **ទរូបា** **ពាក្យផ្ទុយ** **សរូបា**

ទរូបា *នុ.* ឬ *ន.* (ឥ.សំ.) ស្ត្រីរូបអាក្រក់; ស្ត្រីដែលមានរូបអាក្រក់ប្លែក; ស្ត្រីដែលអាក្រក់, ស្ត្រីគួរខ្ពើម; ស្ត្រីពិការ។

សរូបា *នុ.* ឬ *ន.* (ឥ.សំ.) ស្ត្រីរូបល្អ; ស្ត្រីដែលមានរូបល្អ។

📖 **ទវេធ** **ពាក្យផ្ទុយ** **អទវេធ**

ទវេធ *ន.* (ឥ.សំ.) កំហឹង; កំហុស; សេចក្តីស្អប់; ជម្លោះ; សត្រូវ។

អទវេធ *ន.* (ឥ.សំ.) សេចក្តីមិនវិរោធ; ដំណើរឥតកំហុស, ដំណើរឥតសេចក្តីស្អប់; អ្នកដែលឥតវិរោធ, អ្នកដែលឥតកំហុស។

📖 **ទសទិស** **ពាក្យផ្ទុយ** **សទិស**

ទសទិស *នុ.* (សំ.) ដែលទីទៃពីគ្នា, មិនដូចគ្នា, ខុសគ្នា, ផ្សេងពីគ្នា; ដែលជាទំនាស់នឹងគ្នា, ផ្ទុយគ្នា។

សទិស *នុ.* (ឆ.) ដែលដូចគ្នា, ត្រូវគ្នា, ប្រហែលគ្នា, ស្រដៀងគ្នា, លាំគ្នា។

📖 **ទសទិសន័យ** **ពាក្យផ្ទុយ** **សទិសន័យ**

ទសទិសន័យ *ន.* (ឆ.ក្ត.) ន័យផ្សេងគ្នា។

សទិសន័យ *ន.* (ឆ.ក្ត.) ន័យដូចគ្នា, ន័យស្រដៀងគ្នា។

📖 **ទសទិសពណ៌** **ពាក្យផ្ទុយ** **សទិសពណ៌**

ទសទិសពណ៌ *ន.* (ឆ. និង សំ.ក្ត.) ពណ៌ផ្សេងគ្នា, សម្បុរផ្សេងគ្នា។

សទិសពណ៌ *ន.* (ឆ. និង សំ.ក្ត.) ពណ៌ដូចគ្នា, សម្បុរដូចគ្នា។

📖 **ទសទិសភាព** **ពាក្យផ្ទុយ** **សទិសភាព**

ទសទិសភាព *ន.* (ឆ.ក្ត.) ភាពខុសគ្នា, បែបផ្សេងគ្នា។

សទិសភាព *ន.* (ឆ.ក្ត.) ភាពត្រូវគ្នា, បែបស្រដៀងគ្នា។

📖 **ទសទិសសព្ទ** **ពាក្យផ្ទុយ** **សទិសសព្ទ**

ទសទិសសព្ទ *ន.* (សំ.) សព្ទដែលមានសេចក្តីផ្សេងគ្នា, ពាក្យផ្ទុយ :

❖ ពាក្យខុសជាវិសទិសសព្ទរបស់ពាក្យត្រូវ។

សទិសសព្ទ *ន.* (សំ.) សព្ទដែលមានសេចក្តីលាំគ្នា, សព្ទដែលមានសេចក្តីស្រដៀងគ្នា :

- ❖ ផ្តែផ្តា
- ❖ ឧត្តម
- ❖ ខ្ពង់ខ្ពស់។

🕮 ទសតាត ពាក្យផ្ទុយ សតាត

ទសតាត *នុ.* ឬ *ន.* (ឋា.) ដែលមានចំណែកមិនស្មើគ្នា គឺដែលខុសគ្នា, ដែលជាទំនាស់នឹងគ្នា, ដែលផ្ទុយគ្នា; ដែលជាសត្រូវ។

សតាត *នុ.* (ឋា.) ដែលមានចំណែកស្មើគ្នា គឺដែលត្រូវគ្នា, ដែលដូចគ្នា; ដែលត្រូវចិត្តត្រូវគំនិតគ្នា, ដែលជិតដិតស្និទ្ធស្នាលនឹងគ្នា។

🕮 ទសម ពាក្យផ្ទុយ សម

ទសម *នុ.* (ឋា.សំ.) ដែលមិនស្មើ, ដែលមិនរាប, ដែលមិនរាបទាប, ដែលខ្ពស់ៗទាបៗ។

សម *នុ.* (ឋា.សំ.) ដែលស្មើគ្នា, ដែលប៉ុនគ្នា, ដែលប្រហែលគ្នា; ដែលស្រដៀងគ្នា។

🕮 ទសមចិត្ត ពាក្យផ្ទុយ សមចិត្ត

ខសមចិត្ត *ន.* (ឃ.) ចិត្តមិនស្មើ; ចិត្តមិនដូចគ្នា។

សមចិត្ត *ន.* (ឃ.) ចិត្តស្មើ; ចិត្តដូចគ្នា។

📖 **ខសមានចិត្ត ពាក្យផ្ទុយ សមានចិត្ត**

ខសមានចិត្ត *ន.* (ឃ.) ចិត្តមិនស្មោះស្មើ, ចិត្តប្រកបដោយសេចក្តីរង្កៀស, ចិត្តអធ្យាស្រ័យមិនត្រូវគ្នា; សេចក្តីគ្នាន់ក្នាញ់, ការមួម៉ៅក្តៅក្រហាយ។

សមានចិត្ត *ន.* (ឃ.) ចិត្តស្មោះស្មើ, ចិត្តដែលមានសភាពទោរទន់រកគ្នាដោយសេចក្តីស្រលាញ់។

📖 **ខសាទិស ពាក្យផ្ទុយ សាទិស**

ខសាទិស *នុ.* (សំ.) ដែលទីទៃពីគ្នា, ដែលមិនដូចគ្នា, ដែលខុសគ្នា, ដែលផ្សេងពីគ្នា; ដែលជាទំនាស់នឹងគ្នា, ដែលផ្ទុយគ្នា។

សាទិស *នុ.* (សំ.) ដែលដូចគ្នា, ដែលត្រូវគ្នា, ដែលប្រហែលគ្នា, ដែលស្រដៀងគ្នា, ដែលលាំគ្នា។

📖 **ខសាមញ្ញនាម ពាក្យផ្ទុយ សាមញ្ញនាម**

ខសាមញ្ញនាម *ន.* (ឃ.) នាមនាមដែលមិនទូទៅ។

សាមញ្ញនាម *ន.* (ឃ.) នាមនាមដែលនៅទូទៅទៀតបាន។

📖 **ខសារធ ពាក្យផ្ទុយ អត្ថសារធ**

ទសារទ *នុ.* (ឋ.សំ.) ដែលក្លៀវក្លា, ដែលអង់អាច, ដែលឈ្លាសវៃក្នុងការនិយាយស្តី, ដែលឈ្លាសវៃក្នុងការជជែក (ក្នុងករណីលក្ខណៈជំនុំ) :

❖ មនុស្សទសារទ។

អទសារទ *នុ.* (ឋ.សំ.) ដែលមិនក្លៀវក្លា, ដែលមិនអង់អាច, ដែលមិនឈ្លាសវៃក្នុងការនិយាយស្តី, ដែលមិនឈ្លាសវៃក្នុងការជជែក (ក្នុងនីប្រជុំ) :

❖ មនុស្សអទសារទ។

🕮 **ទសារទតាព ពាក្យផ្ទុយ អទសារទតាព**

ទសារទតាព *ន.* (ឋ.ភ្ជ.) ភាពអង់អាច, សេចក្តីអង់អាច :

❖ មានទសារទភាព

❖ ទសារទភាពរបស់អ្នករៀន។

អទសារទតាព *ន.* (ឋ.ភ្ជ.) ភាពជាអ្នកមិនក្លៀវក្លា, ភាពមិនអង់អាច។

🕮 **ទសប្បាសិក ពាក្យផ្ទុយ អទសប្បាសិក**

ទសប្បាសិក *នុ.* (ឋ.) ដែលមានវិស្បាសៈ; ដែលប្រកបដោយសេចក្តីស្និទ្ធស្នាល :

❖ មនុស្សទសប្បាសិក។

អទសប្បាសិក *នុ.* (ឋ.) ដែលមិនមានវិស្បាសៈ, ដែលមិនប្រកបដោយ

សេចក្តីស្និទ្ធស្នាល :

❖ មនុស្សអវិស្សាសិក។

📖 ឧស្សាសិកដ្ឋាន ពាក្យផ្ទុយ អឧស្សាសិកដ្ឋាន

ឧស្សាសិកដ្ឋាន *ន.* (ឋា.) ទីដែលប្រកបដោយវិស្សាស:។

អឧស្សាសិកដ្ឋាន *ន.* (ឋា.) ទីដែលមិនមានវិស្សាស:។

📖 ឧស្សាសិកា ពាក្យផ្ទុយ អឧស្សាសិកា

ឧស្សាសិកា *នុ.* ឬ *ន.* (ឋា.) ដែលមានវិស្សាស:; ស្ត្រីដែលប្រកបដោយសេចក្តីស្និទ្ធស្នាល :

❖ មនុស្សវិស្សាសិកា។

អឧស្សាសិកា *នុ.* ឬ *ន.* (ឋា.) ដែលមិនមានវិស្សាស:; ស្ត្រីដែលមិនប្រកបដោយសេចក្តីស្និទ្ធស្នាល :

❖ មនុស្សអវិស្សាសិកា។

📖 ឧហិច្ឆា ពាក្យផ្ទុយ អឧហិច្ឆា

ឧហិច្ឆា *ន.* (ឋា.ក្ល.) សេចក្តីបៀតបៀន, ការធ្វើឱ្យគេបានសេចក្តីទុក្ខពិបាក, ការធ្វើទុក្ខបុកម្នេញគេ។

អឧហិច្ឆា *ន.* (ឋា.ក្ល.) ការមិនបៀតបៀនគេ, ការមិនធ្វើគេឱ្យបានសេចក្តី

ទុក្ខលំបាក, ការមិនធ្វើទុកបុកម្នេញគេ។

📖 ឧហឹសា ពាក្យផ្ទុយ អឧហឹសា

ឧហឹសា *ន.* (**ឃ.**) សេចក្តីបៀតបៀន, ការធ្វើឱ្យគេបានសេចក្តីទុក្ខពិបាក, ការធ្វើទុក្ខបុកម្នេញគេ។

អឧហឹសា *ន.* (**ឃ.**) ការមិនបៀតបៀនគេ, ការមិនធ្វើគេឱ្យបានសេចក្តីទុក្ខលំបាក, ការមិនធ្វើទុកបុកម្នេញគេ។

📖 ឧហេសា ពាក្យផ្ទុយ អឧហេសា

ឧហេសា *ន.* (**ឃ.**) សេចក្តីបៀតបៀន, ការធ្វើឱ្យគេបានសេចក្តីទុក្ខពិបាក, ការធ្វើទុក្ខបុកម្នេញគេ។

អឧហេសា *ន.* (**ឃ.**) ការមិនបៀតបៀនគេ, ការមិនធ្វើគេឱ្យបានសេចក្តីទុក្ខលំបាក, ការមិនធ្វើទុកបុកម្នេញគេ។

📖 ឧតិក្កម ពាក្យផ្ទុយ អឧតិក្កម

ឧតិក្កម *ន.* (**ឃ.**) អជ្ឈាចារ, ការកន្តងបញ្ញត្តិ, ការល្មើសបញ្ញត្តិ, ការបំពានច្បាប់។

អឧតិក្កម *ន.* (**ឃ.**) ការមិនកន្តងបញ្ញត្តិ, ការមិនល្មើសបញ្ញត្តិ, ការមិនបំពានច្បាប់។

📖 ទីតភ្ជមចេតនា ពាក្យផ្ទុយ អទីតភ្ជមចេតនា

ទីតភ្ជមចេតនា ន. (ឯ.) គំនិតដែលបម្រុងនឹងកន្តង, គំនិតដែលបម្រុងនឹងបំពានលើបញ្ញត្តិ។

អទីតភ្ជមចេតនា ន. (ឯ.) ចេតនាដែលប្រុងប្រយត្នមិនបម្រុងនឹងកន្តង, ចេតនាដែលប្រុងប្រយត្នមិនបម្រុងនឹងបំពានលើបញ្ញត្តិ។

📖 ទីតក្រម ពាក្យផ្ទុយ អទីតក្រម

ទីតក្រម ន. (សំ.) អជ្ឈាចារ, ការកន្តងបញ្ញត្តិ, ការល្មើសបញ្ញត្តិ, ការបំពានច្បាប់។

អទីតក្រម ន. (សំ.) ការមិនកន្តងបញ្ញត្តិ, ការមិនល្មើសបញ្ញត្តិ, ការមិនបំពានច្បាប់។

📖 សកម្មកិរិយា ពាក្យផ្ទុយ អកម្មកិរិយា

សកម្មកិរិយា ន. (ឯ.) កិរិយាសព្ទដែលកាលណានិយាយត្រូវស្រែកហៅអំពើដែលត្រូវធ្វើមកផង, ដូចជា ធ្វើ, ស៊ី, ឧទ្ទល, ទាយ, បិទ ជាដើម។

អកម្មកិរិយា ន. (ឯ.) កិរិយាសព្ទដែលកាលណានិយាយមិនបាច់ដាក់អំពើដែលត្រូវធ្វើមកផងទេ, ដូចជា ដេក, ដួល, ឈរ, អង្គុយ ជាដើម។

📖 សកម្មធាតុ ពាក្យផ្ទុយ អកម្មធាតុ

សកម្មធាតុ *ន.* (**ឋា.**) ឫសដើមរបស់កិរិយាសព្ទប្រកបដោយកម្ម, កាលណានិយាយត្រូវដាក់ពាក្យជាអំពើដែលត្រូវធ្វើមកផង។

អកម្មធាតុ *ន.* (**ឋា.**) ឫសដើមនៃកិរិយាសព្ទដែលមិនមានកម្ម។

📖 **សង្ខតធម៌ ពាក្យផ្ទុយ អសង្ខតធម៌**

សង្ខតធម៌ *ន.* (**ឋា.** និង **សំ.**) ធម៌ដែលបច្ច័យប្រជុំតាក់តែង, សង្ខារធម៌ :

❖ សកលលោកជាសង្ខតធម៌។

អសង្ខតធម៌ *ន.* (**ឋា.** និង **សំ.**) ធម៌ដែលបច្ច័យប្រជុំតាក់តែងពុំបាន :

❖ ព្រះនិព្វានជាអសង្ខតធម៌។

📖 **សន្ដានិម ពាក្យផ្ទុយ អសន្ដានិម**

សន្ដានិម *ឬ.* (**ឋា.ឬ.**) ដែលនាំយកទៅមកបាន, ដែលលើកយកទៅមកបាន, ដែលអាចធ្វើឱ្យកក្រើក, ដែលអាចធ្វើឱ្យឃ្លាតចាកទីបាន :

❖ ថាន

❖ កៅអី។

អសន្ដានិម *ឬ.* (**ឋា.ឬ.**) ដែលនាំយកទៅមកពុំបាន, ដែលលើកយកទៅមកពុំបាន, ដែលពុំអាចធ្វើឱ្យកក្រើក, ដែលពុំអាចធ្វើឱ្យឃ្លាតចាកទីបាន :

❖ ស្រែ

❖ ចម្ការ។

📖 សតេកិច្ចៈ ពាក្យផ្ទុយ អតេកិច្ចៈ

សតេកិច្ចៈ *គុ.* (**ឋ.ក្ត.**) ដែលគួរការក្សាបាននៅឡើយ, ដែលនៅកែបាន :

❖ ទោសនុ៎ះជាសតេកិច្ចៈ។

អតេកិច្ចៈ *គុ.* (**ឋ.ក្ត.**) ដែលមិនគួរការក្សាបាន, ដែលអស់កែបាន, ដែលកែខែលែងកើត :

❖ ទោសនុ៎ះជាអតេកិច្ចៈ។

📖 សតេកិច្ចា ពាក្យផ្ទុយ អតេកិច្ចា

សតេកិច្ចា *គុ.* (**ឋ.**) ដែលគួរការក្សាបាននៅឡើយ, ដែលនៅកែបាន :

❖ ទោសនុ៎ះជាសតេកិច្ចា។

អតេកិច្ចា *គុ.* (**ឋ.**) ដែលមិនគួរការក្សាបាន, ដែលអស់កែបាន, ដែលកែខែលែងកើត :

❖ ទោសនុ៎ះជាអតេកិច្ចា។

📖 សត្យ ពាក្យផ្ទុយ អសត្យ

សត្យ *គុ.* (**សំ.**) ដែលទៀង, ទៀងត្រង់, ពិត, ប្រាកដ, មែន :

❖ ពាក្យសត្យ។

អសត្យ *ន.* (*សំ.*) ដែលមិនទៀង, ដែលមិនពិត :

❖ សម្តីអសត្យ។

📖 សន្តិសុខ ពាក្យផ្ទុយ អសន្តិសុខ

សន្តិសុខ *ន.* (**ឋា.**) សុខដែលកើតអំពីសេចក្តីស្ងប់។

អសន្តិសុខ *ន.* (**ឋា.**) ការមិនមានសេចក្តីសុខសាន្ត, ដំណើរដែលឥតមានសេចក្តីស្ងប់រៀបរយក្នុងស្រុក, ចលាចល, ការរបៈរបោរ។

📖 សន្ទិដ្ឋមិត្ត ពាក្យផ្ទុយ សម្ភត្តមិត្ត, អទិដ្ឋមិត្ត

សន្ទិដ្ឋមិត្ត *ន.* (**ឋា.**) មិត្តដែលគ្រាន់តែបានជួបឃើញគ្នាមួយដងមួយកាលមិនសូវស្និទ្ធស្នាលប៉ុន្មាន, មនុស្សស្គាល់គ្នា :

❖ លុះខ្ញុំទៅដល់ទីនុះ មានពួកសន្ទិដ្ឋមិត្តនិងសម្ភត្តមិត្តមកទទួលឈូឆរអបអរសាទរ។

សម្ភត្តមិត្ត *ន.* (**ឋា.**) មិត្តជិតដិតទុកចិត្តស្និទ្ធស្នាលយ៉ាងមាំ (ឧទ្ធមិត្ត) :

❖ អ្នកនុះជាសម្ភត្តមិត្តរបស់ខ្ញុំ។

អទិដ្ឋមិត្ត *ន.* (**ឋា.**) មិត្តមិនដែលឃើញគ្នា គឺអ្នកដែលរាប់អានគ្នាជាមិត្តប៉ុន្តែមិនដែលបានជួប មិនដែលបានឃើញគ្នាសោះគ្រាន់តែបានផ្ញើសំបុត្រឬផ្តាំដំណឹងទៅវិញទៅមករកគ្នា ឬក៏ផ្ញើទ្រព្យរបស់ភស្តុភារអ្វីៗទៅវិញទៅមក

ដោយអ្នកដទៃ។

📖 សប្បុរសៈ ពាក្យផ្ទុយ អសប្បុរសៈ

សប្បុរសៈ *ន.* (**ឃ.ក្ល.**) បុរសអ្នកស្លប់ គឺមនុស្ស (ប្រុសក្តីស្រីក្តី) អ្នកមិនធ្វើអំពើអាក្រក់ដោយកាយវាចាចិត្ត, អ្នកប្រព្រឹត្តល្អ, អ្នកត្រឹមត្រូវ។

អសប្បុរសៈ *ន.* (**ឃ.ក្ល.**) បុរសអ្នកមិនស្លប់ គឺបុរសស្ត្រីអ្នកកាន់អំពើអាក្រក់ដោយកាយវាចាចិត្ត; អ្នកមានចិត្តអាក្រក់។

📖 សប្បុរិសៈ ពាក្យផ្ទុយ អសប្បុរិសៈ

សប្បុរិសៈ *ន.* (**ឃ.**) បុរសអ្នកស្លប់។

អសប្បុរិសៈ *ន.* (**ឃ.**) បុរសអ្នកមិនស្លប់។

📖 សប្បុរិសកម្ម ពាក្យផ្ទុយ អសប្បុរិសកម្ម

សប្បុរិសកម្ម *ន.* (**ឃ.**) អំពើរបស់សប្បុរស, កិច្ចការរបស់សប្បុរស។

អសប្បុរិសកម្ម *ន.* (**ឃ.**) អំពើរបស់អសប្បុរស, កិច្ចការរបស់អសប្បុរស។

📖 សប្បុរិសចរិយា ពាក្យផ្ទុយ អសប្បុរិសចរិយា

សប្បុរិសចរិយា *ន.* (**ឃ.**) ការប្រព្រឹត្តរបស់សប្បុរស។

អសប្បុរិសចរិយា *ន.* (**ឃ.**) ចរិយារបស់អសប្បុរស។

📖 សប្បុរិសជាត ពាក្យផ្ទុយ អសប្បុរិសជាត

សប្បុរិសជាតិ *ន.* (ឃ.) ជាតិរបស់សប្បុរស។

អសប្បុរិសជាតិ *ន.* (ឃ.) ជាតិនៃអសប្បុរស។

📖 **សប្បុរិសទាន** **ពាក្យផ្ទុយ** **អសប្បុរិសទាន**

សប្បុរិសទាន *ន.* (ឃ.) ទានរបស់សប្បុរស គឺទានដែលគេឱ្យដោយគោរព។

អសប្បុរិសទាន *ន.* (ឃ.) ទានរបស់អសប្បុរស គឺទានដែលគេឱ្យដោយខ្ជីខ្ជា។

📖 **សប្បុរិសធម៌** **ពាក្យផ្ទុយ** **អសប្បុរិសធម៌**

សប្បុរិសធម៌ *ន.* (ឃ. និង សំ.) ធម៌របស់សប្បុរស។

អសប្បុរិសធម៌ *ន.* (ឃ. និង សំ.) ធម៌របស់អសប្បុរស។

📖 **សព្វិ** **ពាក្យផ្ទុយ** **អសព្វិ**

សព្វិ *អ.និ.* (ឃ.) ដោយសប្បុរសទាំងឡាយ, ជាមួយនឹងពួកសប្បុរស។

អសព្វិ *អ.និ.* (ឃ.) ដោយអសប្បុរសទាំងឡាយ, ជាមួយនឹងពួកអសប្បុរស។

📖 **សព្វិកម្ម** **ពាក្យផ្ទុយ** **អសព្វិកម្ម**

សព្វិកម្ម *ន.* (ឃ.) អំពើរបស់ពួកសប្បុរស។

អសព្វិកម្ម *ន.* (ឃ.) អំពើរបស់ពួកអសប្បុរស។

📖 **សព្វិធម៌** **ពាក្យផ្ទុយ** **អសព្វិធម៌**

សព្វិធម៌ *ន.* (ឃ. និង សំ.) ធម៌របស់ពួកអ្នកស្ងប់។

អសប្បិធម៌ *ន.* (ឥ. និង *សំ.*) ធម៌របស់ពួកអសប្បុរស។

📖 សប្បិនា ពាក្យផ្ទុយ អសប្បិនា

សប្បិនា *ន.* (ឥ.) សម្តីរបស់ពួកសប្បុរស។

អសប្បិនា *ន.* (ឥ.) សម្តីរបស់ពួកអសប្បុរស។

📖 សប្បិនាឧ ពាក្យផ្ទុយ អសប្បិនាឧ

សប្បិនាឧ *ន.* (ឥ.) សម្តីរបស់ពួកសប្បុរស។

អសប្បិនាឧ *ន.* (ឥ.) សម្តីរបស់ពួកអសប្បុរស។

📖 សម្ផិន្ន ពាក្យផ្ទុយ អសម្ផិន្ន

សម្ផិន្ន *កិ.* ឬ *នុ.* (ឥ.*សំ.*) បែកហើយ, ផ្លាយហើយ; ដែលបែកហើយ, ដែលផ្លាយហើយ; ដែលបែកបាក់គ្នា។

អសម្ផិន្ន *កិ.* ឬ *នុ.* (ឥ.*សំ.*) មិនបែក, មិនផ្លាយ; ដែលមិនបែក, ដែលមិនផ្លាយ; ដែលមិនលាយច្រលំ, ដែលមិនច្រលំបល់, ដែលមិនច្របូកច្របល់; ដែលមិនឈ្លោះប្រកែកបែកបាក់គ្នា។

📖 សម្ផិន្នញ្ញាត ពាក្យផ្ទុយ អសម្ផិន្នញ្ញាត

សម្ផិន្នញ្ញាត *នុ.* ឬ *ន.* (ឥ.) ញាតិដែលបែកគ្នា; ដែលកើតឈ្លោះប្រកែកបែកបាក់គ្នា។

អសម្ផិន្នញ្ញាត ន. (ឋា.) ញាតិដែលមិនឈ្លោះប្រកែកបែកបាក់គ្នា; ញាតិពិត។

📖 **សម្ផិន្នពជ្ឈ** **ពាក្យផ្ទុយ** **អសម្ផិន្នពជ្ឈ**

សម្ផិន្នពជ្ឈ ន. (ឋា.ក្ល.) ពង្សដែលបែកគ្នា, ត្រកូលដែលបែកគ្នា។

អសម្ផិន្នពជ្ឈ ន. (ឋា.ក្ល.) ពង្សដែលមិនលាយច្រលំគ្នា, ត្រកូលដែលមិនលាយច្រលំគ្នា, ពង្សមិនច្របូកច្របល់គ្នា, ត្រកូលដែលមិនច្របូកច្របល់គ្នា។

📖 **សម្ផិន្នវជ្ឈ** **ពាក្យផ្ទុយ** **អសម្ផិន្នវជ្ឈ**

សម្ផិន្នវជ្ឈ ន. (ឋា.ក្ល.) វង្សដែលបែកគ្នា, ត្រកូលដែលបែកគ្នា។

អសម្ផិន្នវជ្ឈ ន. (ឋា.ក្ល.) វង្សដែលមិនលាយច្រលំគ្នា, ត្រកូលដែលមិនលាយច្រលំគ្នា, វង្សមិនច្របូកច្របល់គ្នា, ត្រកូលដែលមិនច្របូកច្របល់គ្នា។

📖 **សម្ផុតសជ្ឈ** **ពាក្យផ្ទុយ** **អរិយសជ្ឈ**

សម្ផុតសជ្ឈ ន. (ឋា.) ភិក្ខុសង្ឃបុថុជ្ជនដែលបានឧបសម្បទាដោយញត្តិចតុត្ថកម្មវាចា (ព.ពុ.)។

អរិយសជ្ឈ ន. (ឋា.) សង្ឃជាអរិយបុគ្គល (ព.ពុ.)។

📖 **សម្រិត** **ពាក្យផ្ទុយ** **សំរូប**

សម្រិត គុ. ដែលស្រិតរួចហើយ (ប្រើចំពោះតែអង្គរ) :

❖ អង្គរសម្រិត។

សំរូប *គុ.* ដែលនៅមិនទាន់ស្រិត (ចំពោះតែអង្ករ) :

❖ អង្ករសំរូប។

📖 **សខញ្ញាឈាក: ពាក្យផ្ទុយ អខញ្ញាឈាក:**

សខញ្ញាឈាក: *គុ.* (**ឃ.ក្ត.**) ដែលមានវិញ្ញាណ។

អខញ្ញាឈាក: *គុ.* (**ឃ.ក្ត.**) ដែលឥតវិញ្ញាណ។

📖 **សខញ្ញាឈាកទ្រព្យ ពាក្យផ្ទុយ អសខញ្ញាឈាកទ្រព្យ**

សខញ្ញាឈាកទ្រព្យ *ន.* (**ឃ.** និង **សំ.ក្ត.**) ទ្រព្យមានវិញ្ញាណ :

❖ គោ

❖ ក្របី។

អសខញ្ញាឈាកទ្រព្យ *ន.* (**ឃ.** និង **សំ.ក្ត.**) ទ្រព្យឥតវិញ្ញាណ :

❖ មាស

❖ ប្រាក់។

📖 **សស្សាមិក ពាក្យផ្ទុយ អស្សាមិក**

សស្សាមិក *គុ.* (**ឃ.**) ដែលមានម្ចាស់, ដែលមានចៅហ្វាយនាយ។

អស្សាមិក *គុ.* (**ឃ.**) ដែលឥតម្ចាស់, ដែលឥតចៅហ្វាយនាយ :

❖ របស់អស្សាមិក

❖ មនុស្សអស្សាមិក។

📖 សស្សាមិកា ពាក្យផ្ទុយ អស្សាមិកា

សស្សាមិកា *នា.* (ឥ.) ដែលមានស្វាមី, ដែលមានប្តី, ដែលមានប្តីហើយ។

អស្សាមិកា *នា.* (ឥ.) ដែលឥតស្វាមី, ដែលឥតប្តី; ដែលពុំទាន់មានប្តីនៅឡើយ។

📖 ស៊ីយ ពាក្យផ្ទុយ ហោច

ស៊ីយ *កិ.* ឬ *នា.* (ចិ.) មិនប្រទះលាភ, ឃ្លាងលាភ; មិនសមបំណង; មោឃៈ, ឃែត, ឥតបានអ្វី។

ហោច *នា.* (ចិ.) ដែលចម្រើន, ដែលឡើងដៃ, ដែលមានលាភ, ដែលមានចំណេញ, ដែលសមប្រកប; ដែលមានជោគ។

📖 សាធារណៈ ពាក្យផ្ទុយ អសាធារណៈ

សាធារណៈ *នា.* (ឥ.សំ.ក្ល.) ដែលទូទៅ; ដែលទុកជាកណ្តាល, ដែលប្រើបានទាំងអស់គ្នា, ដែលមិនចំពោះមួយៗ; សាមញ្ញ, ដែលរាប់រយរាប់ពាន់។

អសាធារណៈ *នា.* (ឥ.សំ.ក្ល.) ដែលមិនមែនសាធារណៈ, ដែលមិនទូទៅ, ដែលចំពោះតែមួយៗ; ផ្ទាល់ខ្លួន។

📖 សាធារណដ្ឋាន ពាក្យផ្ទុយ អសាធារណដ្ឋាន

សាធារណដ្ឋាន *ន.* (ឥ.) ទីដែលទៅមក, ទីប្រើប្រាស់បានទាំងអស់គ្នា។

អសាធារណដ្ឋាន ន. (ឋា.) កន្លែងសម្រាប់ជនម្នាក់ៗ។

📖 **សាធារណទាន ពាក្យផ្ទុយ អសាធារណទាន**

សាធារណទាន ន. (ឋា.) ទានដែលឱ្យដល់ជនទូទៅមិនរើសមុខ។

អសាធារណទាន ន. (ឋា.) ទានដែលទាយកឱ្យចំពោះបុគ្គល គឺឱ្យសំដៅបុគ្គលម្នាក់ៗមិនទូទៅដល់បុគ្គលឯទៀត, បុគ្គលិកទាន។

📖 **សាធារណទ្រព្យ ពាក្យផ្ទុយ អសាធារណទ្រព្យ**

សាធារណទ្រព្យ ន. (ឋា. និង សំ.ភ្ន.) ទ្រព្យសាមញ្ញ, របស់រាយ។

អសាធារណទ្រព្យ ន. (ឋា. និង សំ.ភ្ន.) ទ្រព្យដែលមិនទូទៅដល់បុគ្គលដទៃ; ទ្រព្យឧត្តម។

📖 **សាធារណនាម ពាក្យផ្ទុយ អសាធារណនាម**

សាធារណនាម ន. (ឋា.) នាមនាមដែលនៅទូទៅទៀតបាន (សាមញ្ញនាម)។

